**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខៈ ១១៤/១៩ គ.ជ.ប.ជ

# របាយការណ៍ឆមាសទី១
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅឆមាសទី២ ឆ្នាំ២០១៩

## I. ស្ថានភាពទូទៅ

រាជរដ្ឋាភិបាលកម្ពុជា ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រ **កម្ពុជា** បានប្តេជ្ញាចិត្តខ្ពស់ ប្រឆាំងការជួញដូរមនុស្ស ដែលជាបទឧក្រិដ្ឋបំផ្លាញមនុស្សជាតិ និងបានដាក់ចេញនូវគោលនយោបាយការងារ គោលនយោបាយសន្តិសុខសង្គម លើកទឹកចិត្តអ្នកវិនិយោគក្នុងប្រទេស និងទាក់ទាញអ្នកវិនិយោគពីបរទេស ដើម្បីបង្កើនការងារជូនពលរដ្ឋក្នុងស្រុក ក៏ដូចជាបើកច្រកឲ្យបញ្ជូនពលករខ្មែរទៅធ្វើការងារស្របច្បាប់ និងមានសុវត្ថិភាពនៅក្រៅប្រទេស ។

ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាប ជាបន្តបន្ទាប់ អាស្រ័យដោយមានការខិតខំប្រឹងប្រែង និងមានកិច្ចសហការគ្នាបានល្អ រវាងក្រសួង ស្ថាប័ន អង្គភាព សមាជិកនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមទាំងលេខាធិការដ្ឋាន នៃគណៈកម្មាធិការថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) និងអង្គការដៃគូទាំងឡាយ ដែលមានសកម្មភាព និងគោលដៅរួមគ្នា។ ការផ្តល់ភាពស្របច្បាប់ជូនពលករកម្ពុជា ប្រមាណមួយលានប្រាំបីម៉ឺននាក់ គឺជាលទ្ធផលជោគជ័យ សម្រាប់ឆ្នាំ២០១៨ របស់រាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ កម្ពុជា ថៃ ។ ទោះបីជាយ៉ាងនេះក្តី ក្នុងឆ្នាំ២០១៩ ក៏នៅមានពលករដែលមិនទាន់មានឯកសារច្បាប់ ត្រូវបានសមត្ថកិច្ចថៃ រកឃើញ ផាកពិន័យ ឃាត់ខ្លួន តម្រូវឲ្យត្រឡប់មករៀបចំឯកសារនៅក្នុងស្រុក ឬបញ្ជូនត្រឡប់ជារៀងរាល់ថ្ងៃ ។ ជនរងគ្រោះមួយចំនួន ត្រូវបានរកឃើញថា កាន់ឯកសារមិនត្រឹមត្រូវ ឬក្លែងបន្លំ និងមិនអាចទទួលផលប្រយោជន៍ស្របច្បាប់បាន ។ នៅមានជនបោកប្រាស់ ដែលបានប្រើរូបភាព ជាភ្នាក់ងារមានសមត្ថកិច្ចផ្តល់ឯកសារក្លែងក្លាយ ជាអ្នករត់ការផ្តល់ភាពស្របច្បាប់ ឬឃោសនាជាអ្នកជ្រើសរើស ដើម្បីបញ្ជូនទៅរកការងារក្រៅប្រទេស ហើយប្រមូលកម្រៃសេវាពីពលករជាដើម ។ សមត្ថកិច្ចថៃ និងកម្ពុជា បានស្រាវជ្រាវ ចាប់ខ្លួន និងផ្តន្ទាទោស ជាបន្តបន្ទាប់ ។

ដោយឡែក បទល្មើសថ្មី ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្សឆ្លងដែន គឺអំពើពពោះជំនួស និងមេខ្យល់នាំស្ត្រីជាកូនក្រមុំឆ្លងដែនស្វែងរកគូស្រករនៅក្រៅប្រទេស ក៏ត្រូវបានរកឃើញ ទប់ស្កាត់ និងបង្ក្រាបបានទាន់ពេលវេលា និងនៅតែបន្តស្រាវជ្រាវ ថែមទៀត ។ ការកសាងច្បាប់ និងបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ក៏ត្រូវបានយកចិត្តទុកដាក់ ផងដែរ ដើម្បីបំពេញភាពខ្វះចន្លោះនៃច្បាប់ ។

ទោះបីជាមានការខំប្រឹងប្រែងផ្សព្វផ្សាយអប់រំ បង្ការទប់ស្កាត់ ដោយផ្ទាល់ និងដោយប្រយោល នៅគ្រប់មជ្ឈដ្ឋាន ច្រកល្ហកយ៉ាងណាក៏ដោយ ក៏នៅតែមានប្រជាពលរដ្ឋ ចាញ់បោកការឃោសនារបស់មេខ្យល់ និងត្រូវ

បានជនខិលខូចឆ្លៀតឱកាស ទាញយកផលចំណេញពីគ្រប់តំណាក់កាលនៃទេសន្តរប្រវេសន៍ ឲ្យធ្លាក់ចូលក្នុងភាពវងគ្រោះ ខូចខាត ទ្រព្យសម្បត្តិ បាត់បង់ផ្ទះសម្បែង បែកបាក់កូនចៅ ក្រុមគ្រួសារ រហូតដល់ពិការ និងបាត់បង់អាយុជីវិត ក្នុងអំពើកេងប្រវ័ញ្ច គ្រប់រូបភាព ដែលហៅថា «ទាសភាពសម័យទំនើប» ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលនៅបន្តកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលដឹកនាំដោយ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិនានា ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដោះស្រាយបញ្ហារួមគ្នា និងទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី** បានរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងច្បាប់ ពីរគឺ ៖
  - ច្បាប់ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
  - ច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**បានចុះអនុស្សរណៈនៃការយោគយល់គ្នារវាង គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ មូលនិធិដើម្បីកុមារ (Child Fund)កម្ពុជា ស្តីពី "សហគមន៍កុមារមេត្រីប្រឆាំងនឹងការជួញដូរកុមារ និងធ្វើចំណាកស្រុកដោយសុវត្ថិភាព" នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៩។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានដឹកនាំគណៈប្រតិភូ មានតំណាងក្រសួង ស្ថាប័ន ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ និងអង្គការមិនមែនរដ្ឋាភិបាល ដោយមាន**ឯកឧត្តម ញឹក ចន្ទ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន**និងយុវនីតិសម្បទា និងខាងភាគីថៃដឹកនាំដោយ**ឯកឧត្តម ឧស្សនី តាំងវ៉ានជិត អនុលេខាធិការអចិន្ត្រៃយ៍ ក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស** បានចុះហត្ថលេខាលើនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពី "ដំណើរការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្ម

ជនរងគ្រោះដោយអំពើជួញដូរមនុស្ស" នៅទីក្រុងបាងកក ប្រទេសថៃ នៅថ្ងៃទី ២៤ ខែមេសា ឆ្នាំ ២០១៩។

- **ក្រសួងអប់រំ យុវជន និងកីឡា៖** កំពុងធ្វើសេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**"។
- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖

  -ប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រី លើកទី២ ដើម្បីអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃប្រទេសម៉ាឡេស៊ី ស្តីពី "**ការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី**"។

  -រៀបចំសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី កិច្ចសហប្រតិបត្តិការក្នុងវិស័យការងាររវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** ធ្វើសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត "**សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ**"។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពី «របបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត» ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ខ.១.១. ការអប់រំផ្សព្វផ្សាយដោយផ្ទាល់

នៅក្នុងឆមាសទី១ ឆ្នាំ២០១៩នេះ សម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាល ក៏ដូចជាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តែងតែដាស់តឿនក្រើនរំលឹក រៀងរាល់កិច្ចប្រជុំ និងកម្មវិធីជាសាធារណៈនានា (ឧទាហរណ៍ ពិធីសម្ពោធសមិទ្ធិផល តាមបណ្តាខេត្តជាដើម) ដល់មន្ត្រីរាជការ អាជ្ញាធរ សមត្ថកិច្ច និងប្រជាពលរដ្ឋ ឲ្យយកចិត្តទុកដាក់ បង្ការទប់ស្កាត់ បង្ក្រាប និងការពារប្រជាពលរដ្ឋពីអំពើជួញដូរមនុស្ស ការអូសទាញពីជនខិលខូច ជាមេខ្យល់ឲ្យធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងដាស់តឿនឲ្យជួយគាំទ្រ និងផ្តល់កិច្ចការពារដល់ជនរងគ្រោះជាដើម។

ចំណែកឯស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយខ្លឹមសារ «**ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព**» ដោយឡែកៗពីគ្នា និងដោយមានកិច្ចសហការជាមួយក្រសួង មន្ទីរពាក់ព័ន្ធ អង្គការដៃគូដល់ប្រជាពលរដ្ឋតាមសហគមន៍ និងតាមវេទិកាសាធារណៈ ដើម្បីពង្រឹងការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងការអប់រំជាប្រចាំដល់

សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ កម្មករ កម្មការិនី និងប្រជាពលរដ្ឋ បានសរុបចំនួន **៣២.០៥០**លើក មានអ្នកចូលរួមសរុបចំនួន **១.៥៧៧.២៩៧**នាក់ ក្នុងនោះស្ត្រីចំនួន **៨៦៥.៧៥១**នាក់ មានដូចតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ៨ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១០ | ៦៨២ | ២៩៥ | ១ | ១២៥ | ៥៧ |
| ២ | ក្រសួងអប់រំ យុវជន និងកីឡា | ៧ | ៦.៥២៥ | ៣.៨៣១ | | | |
| ៣ | ក្រសួងកិច្ចការនារី | ១២ | ២.៤២៤ | ១.៥០៨ | ៩ | ៤៥៤ | ២៥៩ |
| ៤ | ក្រសួងឧស្សាហកម្ម-សិប្បកម្ម | ១៦ | ១៩៧ | ៦៥ | | | |
| ៥ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៨៧៧ | ៦៥.២៧២ | ៣៤.២៤៩ | | | |
| ៦ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ (បញ្ច្រាបសារស្តីពី ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សក្នុងមហោស្រពសិល្បៈយុវជន) | | | | ១ | ៤.០០០ | ០ |
| ៧ | ក្រសួងសុខាភិបា (ផ្សព្វផ្សាយច្បាប់ស្តីពី ការគ្រប់គ្រងការបរិច្ចាក ការផ្សាំកោសិកាជាលិកា សរីរាង្គមនុស្ស) | ៦ | ៥១០ | ៩៧ | | | |
| ៨ | កាកបាទក្រហមកម្ពុជា | ២ | ៧៤ | ៧៤ | ៥ | ១០.០៣២ | ៥.៧០៦ |
| ៩ | សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ (ផ្សព្វផ្សាយតាមរោងចក្រ ) | ១៦ | ១.០១៦ | ៩៣៤ | | | |
| **សរុប ក្រសួង ស្ថាប័ន** | | **៩៤៦** លើក | **៧៦.៧០០** នាក់ | **៤១.០៥៣** នាក់ | **១៦** លើក | **១៤.៦១១** នាក់ | **៦.០២២** នាក់ |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្តាល | ២៣៤ | ១៤.៤៣០ | ៧.៧១៤ | ១.៣៧៦ | ៤៨.១០២ | ២៤.២១១ |
| ៣ | ខេត្តបាត់ដំបង | ៤.០៦០ | ១៩២.៥២៥ | ១០២.២២៥ | ១.៨៤៣ | ៧២.៨៨២ | ៣៧.៨៣០ |
| ៤ | ខេត្តពោធិ៍សាត់ | ២.១៣៨ | ១៦៤.៩៨២ | ៩៦.៣៤៨ | ១.២៥៩ | ៦០.៨៨២ | ៣៣.៣៥៦ |
| ៥ | ខេត្តសៀមរាប | ៤.១៦៣ | ១២៤.៨៤៣ | ៧៥.៤៩៤ | ៦៨៦ | ២៩.៤៤៣ | ១៧.៥៦៧ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៤.១៨០ | ២៥៧.៨១១ | ១៤០.២៧៩ | ២.៥៩៨ | ១១០.០៣២ | ៦១.៥៨១ |
| ៧ | ខេត្តកំពង់ចាម | ២.៥០៤ | ១៣៧.៧៩៧ | ៧៧.៨២២ | ៩៥០ | ៤២.៦៧៩ | ២៤.២២៣ |
| ៨ | ខេត្តព្រះសីហនុ | ១២៩ | ៤.៨៣៧ | ២.២៣៣ | ៦៤ | ១៦០៨ | ៨៣៤ |
| ៩ | ខេត្តព្រះវិហារ | ៤៧ | ៩.៩៦៨ | ៤.៤៦១ | ២៤ | ៥.៥៨៧ | ២.៦១៤ |
| ១០ | ខេត្តស្វាយរៀង | ៦១ | ១.០៩០ | ៦៨០ | ២.០៦៥ | ៨០.៤៣៩ | ៤៥.៦៤៧ |
| ១១ | ខេត្តប៉ៃលិន | ៣២ | ៤.៩២២ | ១.៨៥៨ | ២៥ | ២.៦១១ | ១.៤២២ |
| ១២ | ខេត្តកោះកុង | ១០ | ៨.៦៣៩ | ៣.៩៨១ | ២៥៩ | ៨.១០៧ | ៤.០៤៥ |
| ១៣ | ខេត្តកំពត | ១២ | ៥៣ | ២៨ | ៤៤ | ២.៣៥៣ | ១.៥២៤ |
| ១៤ | ខេត្តកំពង់ធំ | ២ | ៤៣០ | ២៣២ | | | |
| ១៥ | ខេត្តតាកែវ | ៨៩៦ | ៤៩.៩៦៨ | ២៥.០០៨ | ១២៥ | ៤.២១៧ | ១.៩៤៦ |
| ១៦ | ខេត្តក្រចេះ | ១ | ៤៣ | ១៧ | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៧ | ខេត្តកែប | ២៩ | ៦.៧៤៧ | ៣.៥៤១ | ៨១ | ១៨.៨២០ | ៩.១៨២ |
| ១៨ | ខេត្តកំពង់ស្ពឺ | ១៦ | ២.៧៧២ | ១.៣៥២ | | | |
| ១៩ | ខេត្តស្ទឹងត្រែង | ៣ | ២៤៧ | ១៣៥ | ៤ | ២៩៥ | ១៧៩ |
| ២០ | ខេត្តរតនគិរី | ៨៧ | ៥.៦៣៨ | ១.៩៧២ | ៧៨ | ៥.២៤៣ | ២.៤៤៩ |
| ២១ | ខេត្តព្រៃវែង | | | | ១ | ៣០០ | ០ |
| ២២ | ខេត្តត្បូងឃ្មុំ | ១០ | ៤០៥ | ១២៧ | ៧ | ៣៣៩ | ២២៩ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៧៥០ | ១០.៩៤៩ | ៥.៨៣៣ | ២១៥ | ៥.២៦០ | ២.៩៨៦ |
| ២៤ | ខេត្តឧត្តរមានជ័យ | ៣៦ | ២.៣០២ | ១.៥៣៣ | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ១៩.៤០០ លើក | ១.០០១.៣៩៨ នាក់ | ៥៥២.៨៧៣ នាក់ | ១១.៧០៤ នាក់ | ៤៩៩.១៩៩ នាក់ | ២៧១.៨២៥ នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៣២.០៥០ លើក | | ចំនួនមនុស្សសរុប ១.៥៧៧.២៩៧ នាក់ | | ចំនួនស្ត្រី ៨៦៥.៧៥១ នាក់ | |

លើសពីនេះទៅទៀត អង្គការដៃគូមួយចំនួន ក៏បានធ្វើការអប់រំផ្សព្វផ្សាយដោយឡែក ក្នុងគម្រោងកម្មវិធីរបស់ខ្លួន បានជាច្រើនលើកផងដែរ (មានភ្ជាប់ក្នុងឧបសម្ព័ន្ធ) ។

*តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ របស់អង្គការដៃគូនានា*

| ឈ្មោះអង្គការ | សកម្មភាព | ផ្សព្វផ្សាយតាមកម្មវិធីនានា | | |
|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| អង្គការវ៉ាន់អន្តរជាតិ/Sovann Phoum, & CEDAC | បានដាក់បញ្ចូលការផ្សព្វផ្សាយសកម្មភាព បង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយ ប្រថុយប្រថានទៅក្នុងកម្មវិធីវិនិយោគឃុំ/ សង្កាត់ នៅក្នុងខេត្ត ខេត្ត ព្រៃវែង កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ ឧត្តរមានជ័យ និងរាជធានីភ្នំពេញ។ | ០១ | ៤០ | ០០ |
| អង្គការសម្ព័ន្ធចាប់ដៃ | ផ្សព្វផ្សាយស្តីពីការជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទលើកុមារ និងការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព នៅខេត្តកំពង់ឆ្នាំង និងរតនៈគិរី។ | ០២ | ១៣១ | ២១ |
| សរុប | | ០៣ | ១៧១ | ២១ |

**ខ.១.១. ការផ្សព្វផ្សាយតាមរយៈឧបករណ៍ផ្សព្វផ្សាយ**

- **ថ្នាក់ជាតិ**
  - **ក្រសួងអប់រំ យុវជន និងកីឡា** បានបោះពុម្ពប័ណ្ណប្រកាស ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន ៣.០០០ច្បាប់ និងបានចែកចាយទាំង២៥រាជធានី ខេត្ត សម្រាប់ចុះទៅផ្សព្វផ្សាយបន្តនៅតាមសហគមន៍។
  - **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** បានបញ្ចូលសារអប់រំពាក់ព័ន្ធអំពើជួញដូរមនុស្ស ក្នុងផលិតផលភាពយន្ត (CD,VCD,DVD) សរុបចំនួន **៦៥៤.៧១២ឌីស**។
  - **កាកបាទក្រហមកម្ពុជា** បានបោះពុម្ពប័ណ្ណប្រកាសអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព សម្រាប់ចែកជូនសាខារាជធានី-ខេត្ត ដើម្បីផ្សព្វផ្សាយបន្ត ចំនួន **៣.០០០**ច្បាប់។

▪ **សកម្មភាពរបស់អង្គការដៃគូ**

- **អង្គការ Winrock និង Open Institute** សម្ភារៈផ្សព្វផ្សាយ/IEC materials ចំនួន ស្ដីពីពត៌មានអំពីទប់ស្កាត់អំពីជួញដូរ មនុស្ស និងចំណាកស្រុកប្រកបដោយសុវត្ថិភាព ទៅក្នុងរាជធានីភ្នំពេញ ខេត្តស្វាយរៀង កោះកុង ព្រៃវែង កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ សរុបបានចំនួន **១.៦៤៤**នាក់។
- **អង្គការសាម៉ារីតាន់ភើស** បានអប់រំផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ពលករធ្វើចំណាកស្រុក ក្រោយពីអាជ្ញាធរថៃបញ្ជូនមកវិញ សរុបបានចំនួន **៥.៦២៥**នាក់(ស្រី **២.០៤២**នាក់)។

### ខ.១.២. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និង ប្រព័ន្ធអេឡិកត្រូនិក

ក្នុងការអប់រំ ផ្សព្វផ្សាយ តាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក មានរបាយការណ៍ពីខេត្តចំនួន៤ តាមតារាងខាងក្រោម៖

*តារាងនៃការអប់រំផ្សព្វផ្សាយ តាមវិទ្យុទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក*

| ល.រ | ខេត្ត | កម្មវិធី | ចំនួនលើក |
|---|---|---|---|
| ១. | សៀមរាប | ផលិតកម្មវិធី និងចូលរួមជាវាគ្មិន ក្នុងនាទីស្រុកយើង ផ្សាយផ្ទាល់ និងចាក់ផ្សាយឡើងវិញ នៅវិទ្យុ ជាតិ FM វិទ្យុនគរភ្នំ បណ្ដាញទូរទស្សន៍ជាតិ ទូទស្សន៍ខ្សែកាប អង្គរ ប្រព័ន្ធអនឡាញ | ២១៤ លើក |
| ២. | តាកែវ | មន្ទីរព័ត៌មាន ផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធ នឹងការប្រឆាំងអំពើជួញដូរមនុស្ស | ៧៤ លើក |
| ៣. | កំពង់ចាម | ផ្សព្វផ្សាយរឿងអប់រំខ្លីៗ ស្ដីពីចំណាកស្រុក | ០៨លើក |
| ៤. | កោះកុង | វិទ្យុសាគរ នៃមន្ទីរព័ត៌មាន កម្មវិធីពិភាក្សា ស្ដីពីជម្រើសដោយសុវត្ថិភាព៖<br>-ផ្ដោតលើការជួញដូរមនុស្ស<br>-ផ្ដោតលើចំណាកស្រុក | <br>១.២០០ លើក<br>១៥០ លើក |
| សរុប | | | **១.៦៤៦ លើក** |

### ខ.១.៣. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

• **ថ្នាក់ជាតិ**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖

  ○ ជាវាគ្មិនកិត្តិយសក្នុងកិច្ចសន្ទនាគោលនយោបាយថ្នាក់ជាតិ ស្ដីពីអំពើហិង្សាផ្លូវភេទទៅលើកុមារ រៀបចំសម្របសម្រួលដោយអង្គការសីលការ(SILAKA) មានសមាសភាពចូលរួមចំនួន **៤៦**នាក់ (ស្រី **៣៣**នាក់) នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។

  ○ ជាវាគ្មិនក្នុងវេទិកាកុមារ និងអ្នកធ្វើគោលនយោបាយ ដែលមានអ្នកចូលរួមចំនួន **១៨០**នាក់ នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

នៅកម្ពុជា ដោយជានាថាស្ត្រី ក្មេងស្រី និងអ្នកស្រឡាញ់ភេទដូចគ្នាដែលជាក្រុមគោលដៅ ទទួលបានសិទ្ធិអំណាចដើម្បីទាមទារសិទ្ធិរបស់ខ្លួន និងទទួលបានការគាំទ្របន្ថែមពីអាជ្ញាធរ និងសហគមន៍របស់ពួកគេ។

- ក្នុងវេទិកាពិភាក្សាតុមូលរបស់ទូរទស្សន៍ជាតិកម្ពុជា ស្តីពីការលើកកម្ពស់សិទ្ធិកុមារ តាមរយៈការលុបបំបាត់អំពើហិង្សាលើកុមារគ្រប់រូបភាព ក្នុងគោលបំណងបង្កើនការយល់ដឹងដល់សាធារណជន អំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់សិទ្ធិកុមារ និងការការពារកុមារ។

- **ថ្នាក់ក្រោមជាតិ**
  - **ខេត្តបាត់ដំបង៖** បានធ្វើជាវាគ្មិនផ្សព្វផ្សាយការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព ចំនួន ០៥ស្រុក៖
    - ស្រុកថ្មគោល រៀបចំដោយអង្គការ OCE អ្នកចូលរួមចំនួន ៤១នាក់ (ស្រី ២៦នាក់)
    - ស្រុកសំឡូត រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន ១៨នាក់ (ស្រី ១៣នាក់)
    - ស្រុកកំរៀង រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន ២៥នាក់ (ស្រី ១០នាក់)
    - ស្រុកភ្នំព្រឹក រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន ១៧នាក់ (ស្រី ០៧នាក់)
    - ស្រុកភ្នំព្រឹក រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន ២១នាក់ (ស្រី ១២នាក់)
    - ស្រុកសំពៅលូន រៀបចំដោយអង្គការ ការីតាស់ អ្នកចូលរួមចំនួន ១៨នាក់ (ស្រី ១៤នាក់)។
  - **ខេត្តសៀមរាប៖**
    - បានសម្របសម្រួលជូនក្រុមការងារបច្ចេកទេសទទួលជួបអង្គការដៃគូ និងចូលរួមជាវាគ្មិនពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០៤លើក។
    - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមធ្វើជាវាគ្មិនស្តីពី ការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ចំនួន ០៤លើក។
  - **ខេត្តកំពត៖**

    បានចូលរួមជាវាគ្មិនក្នុងកម្មវិធី "**យើងធ្វើបាន**" នៅវិទ្យុFM ៩៩.៧០MHZ ចំនួន ០១លើក។
  - **ខេត្តក្រចេះ៖**

    បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីបញ្ឈប់អំពើហិង្សាលើស្ត្រី និងកុមារ ក្រោមប្រធានបទ "**អំពើហិង្សា និងការរំលោភសេពសន្ថវៈលើស្ត្រី និងកុមារ**" តាមរយៈការផ្សាយសម្លេង និងការឡាយតាមគេហទំព័រហ្វេសប៊ុករបស់វិទ្យុសម្លេងស្ត្រីខេត្តក្រចេះ ចំនួន ០៣លើក។
  - **ខេត្តកំពង់ចាម៖**
    - មន្ទីរព័ត៌មាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធី "**យើងធ្វើបាន**" នៅវិទ្យុFM ៩៩.៧០ MHZ ០១លើក លើប្រធានបទការសម្របសម្រួល និងអន្តរាគមន៍ប្រជាពលរដ្ឋរងគ្រោះដោយការធ្វើចំណាកស្រុកខុសច្បាប់។

○ ស្នងការដ្ឋាននគរបាល និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ លើប្រធានបទ អំពើជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ ជាមួយបុរសជនជាតិចិន។

## ខ.២. ការបង្ការ ទប់ស្កាត់ តាមវិធានការជំនាញ

### ខ.២.១.ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- **ថ្នាក់ជាតិ**
  - **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
    - ក្រសួងបានអនុញ្ញាត និងកំណត់ឲ្យទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជានីមួយ ធ្វើការជ្រើសរើសពលករខ្មែរ មុនបញ្ជូនទៅធ្វើការងារនៅក្រៅប្រទេស ត្រូវធ្វើការបង្ហាត់បង្រៀនភាសា បណ្តុះបណ្តាលជំនាញបឋម របៀបរបបការងារ ច្បាប់ជាធរមាន របស់ប្រទេសទទួលពលករ លក្ខខណ្ឌការងារ និងលក្ខខណ្ឌរស់នៅ ទំនៀមទំលាប់ប្រពៃណីនៃពលរដ្ឋប្រទេសទទួល និងត្រូវរៀបចំឯកសារផ្លូវច្បាប់ ក៏ដូចជាឯកសារបញ្ជាក់ទីកន្លែងធ្វើការជាក់លាក់មុននឹងបញ្ជូនពលករមួយលើកៗ ដោយត្រូវនាំពលករទៅដាក់ឲ្យដល់កន្លែងធ្វើការពិតប្រាកដផងដែរ។
    - បានអប់រំណែនាំតម្រង់ទិសដល់ពលករមុនពេលចេញដំណើរទៅធ្វើការនៅបរទេស សរុបចំនួន **២៦.២៩១**នាក់ (ស្រី **១០ ៥៩៨**នាក់)។
    - បានចុះធ្វើអធិការកិច្ចទីភ្នាក់ងារឯកជនបានចំនួន ៤៦លើក ដើម្បីពង្រឹងសមត្ថភាព និងតម្រង់ទិសការងារ របស់ទីភ្នាក់ងាររបស់ជ្រើសរើសឯកជននីមួយៗ គោរពនិងអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវតាមច្បាប់ និងបទបញ្ញាជាធរមាន ដើម្បីប្រសិទ្ធភាពនៃការការពារ និងលើកកម្ពស់សិទ្ធិពលករខ្មែរនៅក្រៅប្រទេស។
    - បានត្រួតពិនិត្យ ផ្សព្វផ្សាយ និងណែនាំ អំពីនីតិវិធីនៃការជ្រើសរើសកម្មករវ័យក្មេង នៅតាមបណ្តារោងចក្រ សហគ្រាស ដែលមានអ្នកចូលរួមសរុបចំនួន **២៤១**នាក់ (ស្រី **៦២**នាក់)។
    - បានពង្រឹងផ្នែកមណ្ឌលធនធានពលករទេសន្តរប្រវេសន៍ការងារ ដែលមាននៅក្នុងនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងនៅតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំងនៅរាជធានី និងខេត្តទាំង២៤ សម្រាប់ទទួលពិនិត្យ និងដោះស្រាយវិវាទពលករទេសន្តរប្រវេសន៍ និងការផ្តល់ប្រឹក្សាយោបល់។
    - បានចេញសេចក្តីជូនដំណឹងលេខ០៥៦/១៩ក.ប/ស.ណ.ខ.ល ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការហាមក្មេងចូលទៅក្នុងបរិវេណខ្សែសង្វាក់ផលិតកម្ម នៃសិប្បកម្មឡឥដ្ឋ។
  - **ក្រសួងសុខាភិបាលៈ** បានធ្វើសេចក្តីណែនាំជម្រាបដល់មូលដ្ឋានសុខាភិបាលទាំងរដ្ឋ និងឯកជន ដែលកំពុងបម្រើសេវាសុខាភិបាល ដោយមិនអនុញ្ញាតឲ្យធ្វើការផ្សាំ ឬជួញដូរកោសិកាជាលិកា សរីរាង្គមនុស្ស កោសិកាមេជីវិត (ញី ឬឈ្មោល) តាមលិខិតលេខ ១២៥អបស.មព ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៧។
- **ថ្នាក់ក្រោមជាតិ**
  - **ខេត្តកំពង់ឆ្នាំងៈ** មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្ស នៅតាមគ្រឹះស្ថានសិក្សាទាំងអស់ ដល់សិស្សានុសិស្ស នៅពេលគោរពទង់ជាតិ។

### ខ.២.២ការអប់រំណែនាំ និងតម្រង់ទិស

- ថ្នាក់ជាតិ
  - ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ
    - បានអប់រំណែនាំ និងតម្រង់ទិសពលករខ្មែរមុនចេញដំណើរទៅធ្វើការនៅក្រៅប្រទេស សរុបចំនួន ២៦.២៩១នាក់ (ស្រី ១០.៥៩៨នាក់)។

### ខ.២.៣. វិធានការជំនាញអន្តោប្រវេសន៍ ៖ ការគ្រប់គ្រងជនបរទេស

១. <u>ការងារអនុវត្តនីតិវិធី និងការបណ្ដេញចេញជនបរទេសខុសច្បាប់:</u> ជនបរទេសដែលល្មើសច្បាប់ស្ដីពីអន្តោប្រវេសន៍ ត្រូវបានបណ្ដេញចេញពីព្រះរាជាណាចក្រកម្ពុជា សរុបចំនួន ៥៨៧ លើក មនុស្សចំនួន ១.១៩៨នាក់ (ស្រី ១៦៣នាក់) ត្រូវបានបណ្ដេញចេញដោយៈ

- ប្រកាសក្រសួងមហាផ្ទៃ ៣១១លើក មនុស្សចំនួន ៧៨០នាក់ (ស្រី ១៦៣នាក់)។
- បដិសេធមិនឲ្យចូលប្រទេស តាមប៉ុស្ដិ៍ច្រកទ្វារព្រំដែនអន្តរជាតិ ២៧៦លើក មនុស្សចំនួន ៤១៨នាក់។

២. <u>ករណីស្នាក់នៅខុសច្បាប់</u>

- ប្រើប្រាស់លិខិតឆ្លងដែនក្លែងក្លាយ ០៧លើក មនុស្សចំនួន ០៧នាក់ មាន០៧សញ្ជាតិ គឺ ប៉ាគីស្ថាន នីហ្សេរីយ៉ា ស៊ុយអែត អាល្លឺម៉ង់ ក្រូអាត ចិន និងឡាវ។
- ប្រើប្រាស់លិខិតឆ្លងដែនមិនប្រក្រតី ០១លើក មនុស្សចំនួន ០១នាក់ សញ្ជាតិអង់គ្លេស។
- ស្នាក់នៅលើសទិដ្ឋាការ ០១លើក មនុស្សចំនួន ០១នាក់ សញ្ជាតិប៉ាគីស្ថាន។
- គ្មានលិខិតស្នាម ០២លើក មនុស្សចំនួន ១២នាក់ សញ្ជាតិចិន។
- គ្មានលិខិតឆ្លងដែន ០៥លើក មនុស្សចំនួន ១១នាក់ សញ្ជាតិវៀតណាម។
- គ្មានឯកសារគ្រប់គ្រាន់ ០៧លើក មនុស្សចំនួន ១៧នាក់(ស្រី០២នាក់) សញ្ជាតិវៀតណាម១០នាក់ ចិន ០២នាក់ អាហ្វ្រិកខាងត្បូង ០២នាក់ រុស្ស៊ី ០១នាក់ អូស្ត្រាលី ០១នាក់ និងស្កុតឡែន ០១នាក់។
- ហួសទិដ្ឋាការស្នាក់នៅ ០៣លើក មនុស្សចំនួន ០៣នាក់ សញ្ជាតិកូរ៉េ ថៃ និងអាល្លឺម៉ង់។

៣. <u>ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី</u>

ការងារចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេសបែបអន្តោប្រវេសន៍ សរុបមនុស្សចំនួន ៦៦៣នាក់ (ស្រី ៣១៧នាក់) សញ្ជាតិវៀតណាម ក្នុងនោះដកហូតឯកសារ បានចំនួន ៦៤៥ឯកសារ។

### ខ.២.៤. វិធានការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- អគ្គស្នងការដ្ឋាននគរបាលជាតិ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិបានធ្វើបច្ចុប្បន្នភាពលើស្ថិតិពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថា ការធ្វើចំណាកស្រុករបស់ពលរដ្ឋ នៅតែបន្តមានជាប្រក្រតី ជាមធ្យម ប្រមាណជា ៣៦០.០០០នាក់ ក្នុងមួយខែៗ ក្នុងនោះ មានស្ត្រី ប្រមាណ ១៦៣.០០០នាក់ (៤៥.២៧%) និងកុមារប្រមាណ ៨៨០០នាក់ (២.៤៤%) ។ អ្នកចេញដោយស្របច្បាប់ ប្រមាណ ២១០.០០០នាក់ (៥៨.៣៣%) និងមិនស្របច្បាប់ប្រមាណ ៤១.៦៧% ។

*តារាងតាមដានបច្ចុប្បន្នភាពលើទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុក*

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| មករា | ៣៧១.៥៤៧ | ១៦១.២២៣ | ៩.៣៥៦ | ៣.៩៣២ | ២១០.០៨៥ | ៩៥.៣៩០ | ៦៥៤ | ២៧៧ | ១៦១.៤៦២ | ៦៥.៨៣៣ | ៨.៧០២ | ៣.២៥៥ | កើនឡើង ៦៤ |
| កុម្ភៈ | ៣៦៣.៣៥៧ | ១៥៩.៣៨៧ | ១០.២៨០ | ៣.៨២២ | ២០២.៨៨៤ | ៩៤.០០៨ | ១.៥៧៩ | ៥៦២ | ១៦០.៤៧៣ | ៦៥.៣៧៩ | ៨.៧០១ | ៣.២៦០ | ថយចុះ ៨.១៩០ |
| មីនា | ៣៥៨.៩១៣ | ១៥៩.១៤១ | ១០.៥៥៣ | ៤.០៨៧ | ២០៨.៧២៧ | ៩៤.០២០ | ១.៩២៦ | ៨៦៥ | ១៥០.១៨៦ | ៦៥.១២១ | ៨.៦២៧ | ៣.២២២ | ថយចុះ ៤.៤៤៤ |
| មេសា | ៣៥២.៥៣០ | ១៨៤.៥៩៨ | ៨.៦៤១ | ៣.៤២៥ | ២០៧.៧២៥ | ១២០.០៥៨ | ១.៩៩៥ | ៨៧២ | ១៤៤.៨០៥ | ៦៤.៥៤០ | ៦.៦៤៦ | ២.៥៥៣ | កើនឡើង ៦៥៥ |
| ឧសភា | ៣៥១.៩០៥ | ១៥៥.៤០៦ | ៦.៩៣៤ | ២.៧០២ | ២១០.២៥៩ | ៩២.២៥៨ | ៦៥៦ | ២៧៨ | ១៤១៦៤៦ | ៦៣.១៤៨ | ៦.២៧៨ | ២.៤២៤ | ថយចុះ ៦២៥ |
| មិថុនា | ៣៦០.៤៤២ | ១៥៧.៦៤៥ | ៦.៩១២ | ២.៧១៤ | ២១៩.១៤៣ | ៩៣.៨១២ | ៦៥៧ | ២៧៨ | ១៤១.២៩៩ | ៦៣.៨៣៣ | ៦.២៥៧ | ២.៤៣៦ | កើនឡើង ៨.៥៣៧ |

- **ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន វរៈសេនាតូចលេខ៨១៥ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ចំនួន**០១**លើក មនុស្ស **១៣០**នាក់(ស្រី**៥៥**នាក់) អនីតិជន **០៩**នាក់ ដោយបានធ្វើការអប់រំ និងណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។
- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈនគរបាលការពារព្រំដែនគោក វរៈសេនាតូចលេខ ៨១៧ ៨១៩ ៨២៣ និង៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន **២១៦**លើក ពុំបានប្រទះឃើញពលករឆ្លងដែនខុសច្បាប់ទេ។
- **ស្នងការដ្ឋាននគរបាលខេត្តរតនគិរី៖** កម្លាំងល្បាតតាមខ្សែបន្ទាត់ព្រំដែន របស់វរៈនគរបាលការពារព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួន ចំនួន **៥៩**លើក (ព្រំដែនកម្ពុជា-វៀតណាម **៩៨**លើក និងព្រំដែនកម្ពុជា-ឡាវ **០៩**លើក) ដើម្បីទប់ស្កាត់បទល្មើសឆ្លងដែនខុសច្បាប់។

**ខ.២.៤. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត១១ (ខេត្តតាកែវ កែប មណ្ឌលគិរី ក្រចេះ កំពង់ចាម ឧត្តរមានជ័យ រតនៈគិរី កោះកុង បន្ទាយមានជ័យ សៀមរាប និងខេត្តស្វាយរៀង) បានធ្វើសកម្មភាពបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមគោលដៅបម្រើសេវាកំសាន្តដែលអាចបង្កប់សេវាផ្លូវភេទ ដោយចុះធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា និងខារ៉ាអូខេ ដូចមានតារាងខាងក្រោម៖

***តារាងបច្ចុប្បន្នភាពគោលដៅសេវាកំសាន្ត ដែលបានធ្វើការអប់រំដើម្បីបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ក្នុងឆមាសទី១ ឆ្នាំ២០១៩***

| បរិយាយ | ខែមករា | ខែកុម្ភៈ | ខែមីនា | ខែមេសា | ខែឧសភា | ខែមិថុនា |
|---|---|---|---|---|---|---|
| ចំនួនគោលដៅ | ៥៦៣ | ៥៥១ | ៤៦៩ | ៤៤៣ | ៣១០ | ២៨០ |
| ចំនួនមនុស្ស | ២.២៤២នាក់ | ៣.១៩៧នាក់ | ១.៩៣៥នាក់ | ២.៣៤៣នាក់ | ១.៣០៤នាក់ | ១.១៥២ |
| ចំនួនស្ត្រី | ១.៧៩៧នាក់ | ២.២៩២នាក់ | ១.៦២០នាក់ | ១.៩២៧នាក់ | ១.០៩២នាក់ | ៩៥០ |

**ក្នុងនោះ៖**

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ធ្វើបច្ចុប្បន្នភាពគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួន ៧៥គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សចំនួន ០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន ៦៦គោលដៅ។
- ស្នងការដ្ឋាននគរបាលខេត្ត បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទបានចំនួន ២០៩លើក នៅខេត្តក្រចេះ ស្ទឹងត្រែង ព្រះវិហារ ពោធិ៍សាត់ តាកែវ កំពង់ស្ពឺ ស្វាយរៀង និងខេត្តព្រៃវែង។

*ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ*

| ស្នងការដ្ឋានរាជធានី-ខេត្ត | ឆមាសទី១ ឆ្នាំ២០១៩ | | | | | |
|---|---|---|---|---|---|---|
| | ខែមករា | ខែកុម្ភៈ | ខែមីនា | ខែមេសា | ខែឧសភា | ខែមិថុនា |
| | ៣៥ លើក | ៣៩ លើក | ៣៣ លើក | ២២ លើក | ៤៦ លើក | ៣៤លើក |
| សរុប | ២០៩ លើក | | | | | |

**ខ.២.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរូបភាពអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

ក្នុងឆមាសទី១ ឆ្នាំ២០១៩នេះ ក្រសួងការបរទេស និង ប្រកចេញចូលតែមួយ របស់ក្រសួងមហាផ្ទៃ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានទទួលពាក្យ និងធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេស សរុបចំនួន **១.០០៩** គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវ ច្បាប់។ ជំនាញនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទំនាក់ទំនងសាកសួរព័ត៌មានអំពីនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីនៅក្រៅប្រទេស បានចំនួន **៧៤**នាក់ ដើម្បីតាមដានស្ថានភាព ដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

**ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ខេត្តសៀមរាបៈ**

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអធិការកិច្ចពលកម្មកុមារ នៅក្នុងវិស័យឡឥដ្ឋ នៅស្រុកសូទ្រនិគម ស្រុកបន្ទាយស្រី និងស្រុកអង្គរជុំ ដោយក្រុមការងារបានចែកជូនសេចក្តីប្រកាសព័ត៌មាន ស្តីពីករណីគ្រោះថ្នាក់ក្នុងសិប្បកម្មផលិតឥដ្ឋ និងផ្សព្វផ្សាយផលប៉ះពាល់ នៃទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងបានពិនិត្យទៅលើបច្ចេកទេស និងការប្រើប្រាស់កម្លាំងពលកម្ម (ពិសេសពលកម្មកុមារ) បន្ទាប់មកបានធ្វើការណែនាំដល់ម្ចាស់សហគ្រាស ឲ្យមានការប្រុងប្រយ័ត្នចំពោះកុមារដែលធ្វើការនៅក្នុងទីតាំងឡឥដ្ឋរបស់ខ្លួន។

- **ខេត្តកំពង់ធំៈ**
  - មន្ទីរការងារបានចុះពិនិត្យការងារក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារ ចំនួន **០៥**លើក **១២** សាលារៀន ដែលមានយុវជន និងកុមារចូលរួមចំនួន **២៥៧**នាក់ (ស្រី **១៣៦**នាក់)។
  - មន្ទីរ**សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**ខេត្ត បានចុះអធិការកិច្ច វាយតម្លៃកន្លែងថែទាំជំនួសចំពោះកុមារកំព្រាងាយរងគ្រោះដោយអំពើហិង្សា ការធ្វើចំណាកស្រុក ការជួញដូរ ការរំលោភ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងទីទ័លក្រ បានចំនួន **៣១**កន្លែង កុមារ **៨៩២**នាក់ (ស្រី **៤៥២**នាក់) ក្នុងនោះៈ
    - មណ្ឌលថែទាំកុមាររដ្ឋ ចំនួន **១០**មណ្ឌល កុមារ **៣៨៩**នាក់ (ស្រី **១៨០**នាក់)
    - កន្លែងថែទាំសហគមន៍ ចំនួន **១៧**កន្លែង កុមារ **២៨៩**នាក់ (ស្រី **១៣២**នាក់)
    - កន្លែងអន្តេវាសិកដ្ឋានរដ្ឋ ចំនួន **០៣**កន្លែង កុមារ **២១១**នាក់ (ស្រី **១៣៩**នាក់)

○ ផ្ទះសហគមន៍គ្រួសារធម៌ ចំនួន ០១កន្លែង កុមារ ០៣នាក់ (ស្រី ០១នាក់)។

▪ **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអធិការកិច្ចពលកម្មកុមារនៅក្នុង វិស័យឡឥដ្ឋ ចំនួន០៣លើក នៅស្រុកសូទ្រនិគម ស្រុកបន្ទាយស្រី និងស្រុកអង្គរជុំ ដោយក្រុមការងារបានចែកជូនសេចក្តីប្រកាសព័ត៌មាន ស្តីពីករណីគ្រោះថ្នាក់ក្នុងសិប្បកម្មផលិតឥដ្ឋ និងផ្សព្វផ្សាយផលប៉ះពាល់ នៃទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងបានពិនិត្យទៅលើបច្ចេកទេស និងការ។

▪ **ខេត្តព្រះសីហនុ៖**

**ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ** សហការជាមួយអង្គការម្លប់តាប៉ាង ដើម្បីការពារសុវត្ថិភាពកុមារ បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ និងផ្នែកភ្នាក់ងារទេសចរណ៍ សរុបចំនួន **១.១៣៣**នាក់។

▪ **ខេត្តរតនគិរី៖**

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចសាមញ្ញចំនួន **១៩**លើក និងចុះធ្វើអធិការកិច្ចពិសេស **០៨**លើក និងអធិការកិច្ចពិសេសក្រៅកម្មវិធី **០២**លើក ក្នុងគោលបំណងពិនិត្យលើការងារអនុវត្តច្បាប់ ស្តីពីការងារ និងការបង្ការការប្រើប្រាស់កម្លាំងពលកម្មខុសច្បាប់ និងការប្រើប្រាស់ពលកម្មកុមារ។

▪ **ខេត្តស្វាយរៀង៖**

កម្លាំងអធិការដ្ឋាននគរបាលក្រុងបានចុះស្រង់ទិន្នន័យគោលដៅរោងចក្រ សហគ្រាស សិប្បកម្មសង្ស័យអាចពាក់ព័ន្ធការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារចំនួន **០៥**លើក ស្មើ **២០**គោលដៅ មានកម្មករសរុបចំនួន **៦០**នាក់(នីតិជនទាំងអស់) និងបានណែនាំ និងធ្វើកិច្ចសន្យាដល់ម្ចាស់សិប្បកម្មទាំងអស់កុំឲ្យទទួលយកកុមារ(អនីតិជន)មកធ្វើការ។

▪ **ខេត្តប៉ៃលិន៖**

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះអធិការកិច្ច ដើម្បីទប់ស្កាត់ និងលុបបំបាត់ នូវទម្រង់ជួញដូរធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថាន ដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា រោងសម្ងួត និង ថ្លឹងកសិផល កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ២៤០កន្លែង។

▪ **ខេត្តក្រចេះ៖**

○ បានសហការជាមួយអង្គការភូមិកុមារកម្ពុជា SOS ទទួលកុមារមករស់នៅសរុបចំនួន **៩៥**នាក់។
○ បានផ្តល់អាហាររូបត្ថម្ភ និងសម្ភារសិក្សាដល់កុមារក្នុងសហគមន៍ ចំនួន **៤០០**នាក់។
○ ចុះត្រួតពិនិត្យមណ្ឌលអង្គការដំណឹងល្អទាំង៤។

## ២.៤. ការលើកកម្ពស់ជីវភាព

- **ខេត្តសៀមរាប**

ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការសេដាក ផ្សព្វផ្សាយ កសិករឲ្យយល់ដឹងអំពីការជួញដូរមនុស្ស ការជួញដូរកម្លាំងពលកម្ម និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបណ្តុះបណ្តាលការងារធ្វើកសិកម្មធម្មជាតិជាលក្ខណៈគ្រួសារ នៅក្នុងស្រុកគោលដៅចំនួន**០៦** (ស្រុកស្រីស្នំ វ៉ារិន សូទ្រនិគម ជីក្រែង អង្គរជុំ និងស្រុកពួក) មាន **១១**ឃុំ និង **៦១**ភូមិ សរុបបាន **១០**លើក អ្នកចូលរួមចំនួន **៤៣**នាក់(ស្រី **៣១**នាក់)។

### ខ.៥. ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសឯកជន

▪ **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

ទីភ្នាក់ងារជ្រើសរើសឯកជនដែលមានអាជ្ញាប័ណ្ណ និងការជ្រើសរើសតាមប្រព័ន្ធ អនុគ្រោះមុខរបរ Employment Permit System (EPS) របស់រាជរដ្ឋាភិបាលកម្ពុជា និងបានបញ្ជូនពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស សរុបចំនួន **៣០.៦៤៦**នាក់ (ស្រី**១២.៦៩៨**នាក់) ក្នុងនោះ៖

| | | |
|---|---|---|
| - ប្រទេសថៃឡង់ដ៍ | ចំនួន **២៥.៥៧៨**នាក់ | (ស្រី**១១.១៦៤**នាក់) |
| - ប្រទេសជប៉ុន | ចំនួន **១.៦១៥**នាក់ | (ស្រី **៧៣៨**នាក់) |
| - ប្រទេសសឹង្ហបុរី | ចំនួន **៦៧**នាក់ | (ស្រី **៦៧**នាក់) |
| - តំបន់រដ្ឋបាលពិសេសហុងកុង | ចំនួន **២១**នាក់ | (ស្រី **២១**នាក់) |
| - ប្រទេសអារ៉ាប៊ីសាអូឌីត | ចំនួន **៤៧**នាក់ | (ស្រី **៤៧**នាក់) |
| - ប្រទេសម៉ាឡេស៊ី | ចំនួន **៣៩**នាក់ | (ស្រី **២០**នាក់) |

**ជាពិសេសប្រទេសកូរ៉េតាមប្រព័ន្ធអនុគ្រោះមុខរបរ(EPS)** ចំនួន**៣.២៧៩**នាក់ (ស្រី **៦៤១**នាក់)

### ខ.៦. ការផ្តល់ប័ណ្ណព្រំដែនដល់ប្រជាជនចល័តឆ្លងកាត់ព្រំដែន

ដើម្បីសម្រួលដល់ការឆ្លងដែនស្របច្បាប់ របស់ប្រជាជនដែលចល័តឆ្លងកាត់ព្រំដែនរយៈពេលខ្លី រដ្ឋបាលខេត្តចំនួន០៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន ដែលមានច្រកប៉ុស្តិ៍អន្តរជាតិនៅតាមព្រំដែន បានផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ (Border Pass) សរុបចំនួន **៥៤.៣០៤**ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន មាន:

| | |
|---|---|
| ○ ខេត្តបាត់ដំបង | ចំនួន **៣៩.៣៥២**ប័ណ្ណ |
| ○ ខេត្តបន្ទាយមានជ័យ | ចំនួន **១០.៤៤៨**ប័ណ្ណ |
| ○ ខេត្តប៉ៃលិន | ចំនួន **៤.៥០៤**ប័ណ្ណ។ |

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

តាមរបាយការណ៍ពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដែលប្រមូលបានពីជំនាញរបស់នាយកដ្ឋាន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទូទាំងប្រទេស បានបង្ហាញអំពីលទ្ធផលនៃការបង្ក្រាបបទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ថាមានភាពប្រសើរជាងមុន បើប្រៀបធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០១៨ ។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត១៩ បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ**សរុបបាន ៧៨ករណី** លើ**៦២**ករណី (កើនឡើង **១៦**ករណី ស្មើនឹង **២៥%**) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន **៩៧**នាក់/**៨៥**នាក់ (កើន **១២**នាក់ ស្មើនឹង **១៤%**) ក្នុងនោះស្រី **២២**នាក់ អនីតិជន ០៩នាក់ ជាជនបរទេស **១៤**នាក់ សញ្ជាតិចិន **១២**នាក់ និងអាមេរិក ០២នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន **២៦៣**នាក់ (លើ**១០៦**នាក់) កើន១៥៧នាក់ ស្មើនឹង១៤៨% ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ **៧០**នាក់ អាយុ១៥-១៧ឆ្នាំ **៣១**នាក់ និងពី១៨ឆ្នាំឡើង **១៦២**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច **៧២**នាក់ និងប្រគល់ទៅគ្រួសារ **១៩១**នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងបូកសរុបបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទប្រចាំឆមាសទី១*

| ល.រ | បរិយាយ | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| ១ | ត្រីមាសទី១ | ៤២ ករណី | ១៥៧ នាក់ | ៥៥ នាក់ | ចិន១២ អាមេរិក១ |
| ២ | ត្រីមាសទី២ | ៣៦ ករណី | ១០៦ នាក់ | ៤២ នាក់ | អាមេរិក១ |
| **សរុបឆមាសទី១** | | **៧៨/៦២ ករណី** | **២៦៣/១០៦ នាក់** | **៩៧/៨៥ នាក់** | **១៤ នាក់** |

**បែកចេញជា៖**

**១. ករណីអំពើជួញដូរមនុស្ស**

បង្ក្រាបបាន **១២ករណី/១៨ករណី (ថយ៦ករណី ស្មើនឹង ៣៣%)** ឃាត់ខ្លួនជនសង្ស័យចំនួន **១៦នាក់/២៨នាក់** ថយ **១២នាក់** ស្មើនឹង **៤២.៨៥%** (ស្រី **០៨**នាក់ ជនបរទេស **០១**នាក់ សញ្ជាតិអាមេរិក)។

សង្គ្រោះជនរងគ្រោះចំនួន **១០៧**នាក់/**៣២**នាក់ (កើន **៧៥**នាក់ ស្មើនឹង **២៣៤.៣៧%**) ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ **១៩**នាក់ អាយុពី១៥-១៧ឆ្នាំ **២០**នាក់ និងពី១៨ឆ្នាំឡើង **៦៨**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច **១៤**នាក់ និងឲ្យគ្រួសារ **៩៣**នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកអនីតិជនជាអាទ៏ចេញដោយមិនស្របច្បាប់ | ០២ | ០៣ | ០២ | |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ០២ | ៥៣ | ០៤ | |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០៤ | ៣៤ | ០៦ | |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ០១ | ០៥ | ០១ | |
| -អំពើលក់ដូរមនុស្ស | ០១ | ០២ | ០១ | |
| -អំពើនាំឆ្លងដែន | ០១ | ០៥ | ០១ | |
| -ការទិញពេស្យាចារកុមារ | ០១ | ០៥ | ០១ | អាមេរិក ១ |
| *សរុប* | *១២ ករណី* | *១០៧ នាក់* | *១៦ នាក់* | *០១ នាក់* |

**២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ**

បង្ក្រាបបាន **៦៦ករណី/៤៤ករណី កើន២២ករណី ស្មើនឹង ៥០%** ឃាត់ខ្លួនជនសង្ស័យចំនួន **៨១នាក់/៥៧នាក់ កើន២៤នាក់ ស្មើនឹង ៤២.១០%** (ស្រី **១៤**នាក់ អនីតិជន **០៩**នាក់ ជនបរទេស **១៣**នាក់ សញ្ជាតិចិន **១២**នាក់ និងអាមេរិក **០១**នាក់)។

សង្គ្រោះជនរងគ្រោះចំនួន **១៥៦**នាក់/**៧៤**នាក់ កើន៨២នាក់ ស្មើនឹង១១០.៨១% ក្នុងនោះមាន អាយុក្រោម១៥ឆ្នាំ **៥១**នាក់ អាយុ១៥-១៧ឆ្នាំ **១១**នាក់ អាយុពី១៨ឆ្នាំឡើង **៩៤**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច **៥៨**នាក់ និងប្រគល់ទៅគ្រួសារ **៩៨**នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -សញ្ញារកម្ម | ១០ | ៣៩ | ១៤ | ចិន ៥ |
| -សញ្ញារកម្ម(មានអនីតិជន) | ០៣ | ១៥ | ០៣ | |

| | | | | |
|---|---|---|---|---|
| -ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ០១ | ២៧ | ០៧ | ចិន ៧ |
| -សញ្ជារកម្ម( ទាក់ទងនឹងពេស្យាចារកុមារ) | ០៥ | ១៤ | ០៦ | |
| -ការផ្ដល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ | ០២ | ១៣ | ០៦ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៣១ | ៣១ | ៣១ (អនី.៦) | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១៤ | ១៧ | ១៤ (អនី.៣) | អាមេរិក ១ |
| *សរុប* | *៦៦ ករណី* | *១៥៦ នាក់* | *៨១ នាក់* | *១៣ នាក់* |

## គ.២. កិច្ចការយុត្តិធម៌

### គ.១.លទ្ធផលចំណាត់ការផ្តន្ទាទោសក្នុងឆមាសទី១ ឆ្នាំ២០១៩

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ ដូចមានក្នុងតារាងលម្អិតខាងក្រោម៖

**១. ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ៖**

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន **៧៩**ករណី ជនរងគ្រោះចំនួន **១០៣**នាក់ (ស្រី **៨៦**នាក់ អនីតិជន **៦៤**នាក់) ជនត្រូវចោទមានចំនួន **៨៩**នាក់ ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន **៥៥**ករណី តម្កល់ទុកឥតចាត់ការគ្មាន និងកំពុងចាត់ការចំនួន **២៤**ករណី៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូង*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប | ៧ | ៣២ | ៨ | ៥៦ | ៦៦ | ២៣ | ០ | ០ | ៥៥ | ០ | ២៤ |
| ៧៩ | ៣៩ នាក់ | | ៦៤ នាក់ | | ៨៩ នាក់ | | ០ នាក់ | | ៧៩ ករណី | | |

**២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ៖**

ចំណាត់ការរបស់ចៅក្រមស៊ើបសួររាជធានី-ខេត្ត សរុបមានចំនួន **១១៨**ករណី ជនរងគ្រោះចំនួន **១៤២**នាក់ (ស្រី **១១៩**នាក់) អនីតិជន **៩១**នាក់ (ស្រី **៧៧**នាក់) ជនត្រូវចោទមានចំនួន **១៤៣**នាក់ (ស្រី **២៥**នាក់) អនីតិជន **១៧**នាក់(ស្រី ០១នាក់) នៅក្នុងឃុំចំនួន **១១៦**នាក់(ស្រី **១៤**នាក់) នៅក្រៅឃុំចំនួន **២៧**នាក់(ស្រី **១១**នាក់) អនីតិជន **០១**នាក់(ស្រី) និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន **២៥**ករណី លើកលែងចោទគ្មាន និងកំពុងចាត់ការចំនួន **៩៣**ករណី៖

*តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួរ៖*

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | ជូនទៅជម្រះ | លើកលែងចោទ | កំពុងចាត់ការ |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | | | |
| សរុប | ៩ | ៤២ | ១៤ | ៧៧ | ១០២ | ២៤ | ១៦ | ១ | ១០២ | ១៤ | ០ | ០ | ០ | ១០ | ១៦ | ១ | ២៥ | ០ | ៩៣ |
| ១១៨ | ៥១ នាក់ | | ៩១ នាក់ | | ១២៦ នាក់ | | ១៧ក់ | | ១១៦ នាក់ | | | | ២៧ នាក់ | | | | ១១៨ ករណី | | |

### គ.២.៣. ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន **៩៣**ករណី ជនរងគ្រោះចំនួន **១៣៩**នាក់ (ស្រី **១១៣**នាក់) អនីតិជន **១០៧**នាក់(ស្រី **៨៦**នាក់) ជនជាប់ចោទសរុប **១២៦**នាក់(ស្រី **១៨**នាក់) និង ប្រភេទចំណាត់ការ(ទោសព្យួរគ្មាន ពិន័យជាប្រាក់គ្មាន រួចផុតពីបទចោទគ្មាន រំលត់បណ្ដឹងអាជ្ញាគ្មាន ចាត់ការរួច **៣០**ករណី ផ្ដន្ទាទោសដាក់ពន្ធនាគារក្នុងឃុំ **១០១**នាក់ នៅក្រៅឃុំ **២៥**នាក់ និងកំពុងចាត់ការ **៦៣**ករណី)៖

***តារាងចំណាត់ការរឿងក្ដីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះ***

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជន ជាប់ចោទ | | ប្រភេទចំណាត់ការ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្ដឹងអាជ្ញា | ចាត់ការរួច | ផ្ដន្ទាទោសពន្ធនាគារ | | កំពុងចាត់ការ |
| | | | | | | | | | | | | ក្នុងឃុំ | ក្រៅឃុំ | |
| | ប | ស | ប | ស | ប | ស | | | | | | | | |
| សរុប | ៥ | ២៧ | ២១ | ៨៦ | ១០៨ | ១៨ | គ្មាន | គ្មាន | គ្មាន | គ្មាន | ៣០ | ១០១ | ២៥ | ៦៣ |
| ៩៣ | ៣២ នាក់ | | ១០៧ នាក់ | | ១២៦ នាក់ | | | | | | នាក់ | នាក់ | នាក់ | ករណី |

### គ.៣.ការដោះស្រាយករណីវិវាទរវាងពលករទេសន្តរប្រវេសន៍ និងបណ្ដាក្រុមហ៊ុននានា

- **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

បានទទួលនិងដោះស្រាយវិវាទផ្នែក ទេសន្តរប្រវេសន៍ ចំនួន **២៣**ក្រុមហ៊ុន មានសំណុំរឿងចំនួន **២៨**ករណី ក្នុងនោះមានពលករចំនួន **២៦៦**នាក់ (ស្រី **១៣៩**នាក់)។ បណ្ដឹងសះជាចំនួន **០៦**ករណី បណ្ដឹងមោឃៈ **០**ករណី និងបណ្ដឹងកំពុងតាមដានដោះស្រាយបន្តមានចំនួន **២៣**ករណី។

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវាគាំទ្រ

### ឃ.១. ការទទួល ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានសម្របសម្រួលបែបបទបញ្ជូនពលករខ្មែរ ដែលត្រូវមាតុភូមិនិវត្តន៍ និងករណីសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្សពីបរទេស ចំនួន **២១.៧៤៦**នាក់ (ស្រី **៩.៤២៥**នាក់) ក្នុងនោះករណីមួយចំនួន មានកិច្ចសហការ និងគាំទ្រ ពីអង្គការដៃគូ (IOM, សម្ព័ន្ធអង្គការចាប់ដៃ, ...) ៖

| ល.រ. | ឈ្មោះប្រទេសគោលដៅ | មូលហេតុនៃការវិលត្រឡប់ | សរុប | ស្រី | ប្រុស |
|---|---|---|---|---|---|
| ១ | ម៉ាលេស៊ី | ធ្វើការខុសច្បាប់ | ៦ | ៥ | ១ |
| ២ | ចិន | សង្ស័យជួញដូរ និងចាញ់បោកមេខ្យល់ | ៣២ | ២៦ | ៦ |
| ៣ | សឹង្ហបូរី | ទ្រាំការងារមិនបាន | ៣ | ៣ | ០ |
| ៤ | វៀតណាម | លក់ឆ្នោត និងដោះលែងពី | ៤៥ | ៣១ | ១៤ |

| | | | | | |
|---|---|---|---|---|---|
| | | ការបោទប្រកាន់ | | | |
| ៥ | ឡាវ | ពលករខុសច្បាប់ | ១ | ០ | ១ |
| ៦ | ថៃ (ខេត្តស្រះកែវ) | ពលករខុសច្បាប់ | ២១.៦៥៨ | ៩.៣៥៩ | ១២.២៩៩ |
| ៧ | អារ៉ាប៊ីសាអ៊ូឌីត | ពលករខុសច្បាប់ | ១ | ១ | ០ |
| ៨ | ឥណ្ឌូណេស៊ី | ពលករខុសច្បាប់ | ៣ | ១ | ២ |
| | សរុប | | ២១.៧៤៦ | ៩.៤២៥ | ១២.៣២១ |

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានទទួលជនរងគ្រោះ និងងាយរងគ្រោះ ដែលធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសនានា សរុបចំនួន **៨៥** នាក់ (ប្រុស **២១**នាក់ ស្ត្រី **៤៨**នាក់ កុមារា **០៥**នាក់ កុមារី **១១**នាក់) ក្នុងនោះក៏មានកិច្ចសហការពីអង្គការដៃគូផងដែរ (ដូចមានតារាងលម្អិតប្រចាំខែនីមួយៗ) ក្នុងនោះ៖

- **ក្រុមការងារការពារជនរងគ្រោះ** នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា នៅព្រលានយន្តហោះអន្តរជាតិ សរុបចំនួន **៦៣**នាក់(ប្រុស **១៧**នាក់ ស្ត្រី **៤២**នាក់ កុមារី **០៤**នាក់) ក្នុងនោះមានៈប្រទេសចិន **៣៤**នាក់ ម៉ាឡេស៊ី **១៧**នាក់ វៀតណាម **០៦**នាក់ ប្រទេសថៃ **០៤**នាក់ និងអារ៉ាប៊ីសាអូឌីត **០២**នាក់(ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ **៣៨**នាក់ ករណីងាយរងគ្រោះ **១៧**នាក់ ជួញដូរមនុស្ស និងជួញដូរកម្លាំងពលកម្ម **០៦** នាក់)។
- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃ ចំនួន **២២**នាក់(ប្រុស **០៤**នាក់ ស្ត្រី **០៦**នាក់ កុមារា **០៥**នាក់ កុមារី **០៧**នាក់)។

▪ **អគ្គនាយកដ្ឋានអន្តោប្រវេសន៍**

បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកកម្ពុជាវិញ សរុបចំនួន **៥៤២**លើក មនុស្សចំនួន **៦.៧១៤**នាក់ (ស្រី **២.១៦២**នាក់ កុមារ **៦២៥**នាក់)។ ក្នុងនោះតាម៖

- ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ មនុស្សចំនួន **៤៣៨**នាក់ (ស្រី **១៥៥**នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ មនុស្សចំនួន **៦.២៧៣**នាក់ (ស្រី **២.០០៧**នាក់ កុមារចំនួន **៦២៥**នាក់)
- ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម មនុស្សចំនួន **០២**នាក់
- និងមកពីប្រទេសឡាវ មនុស្សចំនួន **០១**នាក់។

▪ **អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែន**

បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិ និងច្រក កម្ពុជា-ថៃ ផ្សេងទៀត សរុបចំនួន **៧.៣៦០**នាក់ (ស្រី **២,៣៤០**នាក់ អនីតិជន **៨៥៦** នាក់) ។

▪ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ចំនួន០៤

បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម សរុបចំនួន ៣៦៧លើក មនុស្សចំនួន ៧.៤១០នាក់ (ស្រី ២.៣៩១នាក់ អនីតិជន ៨៦៨នាក់) ដូចមានតារាងខាងក្រោម៖

| ល.រ. | ច្រកព្រំដែនខេត្ត | ចំនួនលើក | ចំនួនមនុស្សសរុប | ចំនួនស្រី | ចំនួនអនីតិជន |
|---|---|---|---|---|---|
| ១. | បន្ទាយមានជ័យ | ២៩៣ លើក | ៦.៧៤៦ នាក់ | ២.១៥៧ នាក់ | ៨៣១នាក់ |
| ២. | បាត់ដំបង | ៥៧ លើក | ៥៣៨ នាក់ | ១៧៤ នាក់ | ១២ នាក់ |
| ៣. | កោះកុង | ១៤ លើក | ៨១ នាក់ | ២៥ នាក់ | ០០ |
| ៤. | ស្វាយរៀង | ០៣ លើក | ៤៥ នាក់ | ៣៥ នាក់ | ២៥ នាក់ |
| សរុប | ៤ខេត្ត | ៣៦៧ លើក | ៧.៤១០ នាក់ | ២.៣៩១ នាក់ | ៨៥៨ នាក់ |

**ដោយឡែក៖**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួលពលករខ្មែររងគ្រោះ ដែលត្រឡប់ពីបណ្តាប្រទេសផ្សេងៗ សរុបចំនួន **៥៥**នាក់ (ស្រី **៤៦**នាក់) ក្នុងនោះ មកពីប្រទេសចិន**៤០**នាក់ ម៉ាឡេស៊ី **០៤**នាក់ ឥណ្ឌូនេស៊ី **០៦**នាក់ និងប្រទេសវៀតណាម **០៥**នាក់។

• **ក្នុងនោះបានសម្ភាស ចំនួន ៥២នាក់ ៖**

- ទៅតាមរយៈមេខ្យល់ **៤៦**នាក់ (ទៅប្រទេសចិន **៣៨**នាក់, ទៅប្រទេសម៉ាឡេស៊ី **០៣**នាក់ និងទៅប្រទេសវៀតណាម **០៥**នាក់)
- ទៅតាមរយៈក្រុមហ៊ុន **០១**នាក់(ទៅប្រទេសម៉ាឡេស៊ី)
- ទៅដោយខ្លួនឯង **០៥**នាក់ (ទៅប្រទេសឥណ្ឌូនេស៊ី) ។

• **ក្នុងនោះរកឃើញមេខ្យល់ ១២នាក់ (បង្ក្រាបបានតែ ០១នាក់ ចំណែកឯ ១១នាក់ទៀត កំពុងធ្វើការស្រាវជ្រាវ និងអនុវត្តនីតិវិធីតាមផ្លូវច្បាប់។**

*ក្រោយពីការសម្ភាសរួច សមត្ថកិច្ចយើងបានធ្វើការអប់រំ និងបញ្ជូនទៅមូលដ្ឋានវិញ។*

**ឃ.១.២. ការទទួលសាកសពបញ្ជូនត្រឡប់ (៦ខែ)**

▪ **អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែន នៃក្រសួងការពារជាតិ**

តាមទិន្នន័យរបស់សមត្ថកិច្ចតាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ បានទទួលសាកសពពលរដ្ឋខ្មែរដែលបានស្លាប់ដោយសារគ្រោះថ្នាក់ផ្សេងៗ សរុបចំនួន **៧១**សព(ស្រី **១២**សព កុមារ **០១**សព)។

**ឃ.២. ការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ច រាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលបានសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន **៤៣៨**នាក់(ស្ត្រី **២៥០**នាក់ កុមារ **១៥៤**នាក់) មានតារាងលម្អិតដូចខាងក្រោមនេះ៖

*តារាងទទួលជនសង្ស័យរងគ្រោះ និងជនរងគ្រោះ ឆមាសទី១ ឆ្នាំ២០១៩*

| ក្រសួង ស្ថាប័ន | | ជនរងគ្រោះ | | |
|---|---|---|---|---|
| | សរុប | ស្ត្រី | កុមារា | កុមារី |
| នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃក្រសួងសង្គម | ៤២ | ២៦ | ០០ | ០០ |
| មជ្ឈមណ្ឌលសំចតប៉ោយប៉ែត | ១៥២ | ៣៨ | ៤៨ | ៤៨ |
| មន្ទីរសង្គមកិច្ច រាជធានី-ខេត្ត | ១០៨ | ១០៨ | ០០ | ០០ |
| អង្គការដៃគូក្រៅរដ្ឋាភិបាល | ១៣៦ | ៧៨ | ០៨ | ៥០ |
| *សរុប* | *៤៣៨ នាក់* | *២៥០ នាក់* | *៥៦ នាក់* | *៩៨ នាក់* |

- មន្ត្រីជំនាញរបស់**នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃក្រសួង ស.អ.យ** បានសម្ភាស ផ្តល់សេវាពិគ្រោះយោបល់ និងបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ៤២នាក់(ស្ត្រី ២៦នាក់) ទៅទទួលសេវាបន្តនៅអង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា អង្គការ IOM អង្គការរតនៈអន្តរជាតិ និងអង្គការបេសកកម្មអន្តរជាតិ(IJM)។
- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានផ្តល់សេវាស្នាក់នៅរយៈពេលខ្លី និងស្តារនីតិសម្បទា ដល់ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ១៥២នាក់ (បុរស ១៨នាក់ ស្ត្រី ៣៨នាក់ កុមារា ៤៨នាក់ កុមារី ៤៨នាក់) ក្នុងនោះមាន៖ (***ករណីរងគ្រោះដោយអំពើជួញដូរមនុស្ស ២២នាក់ និងងាយរងគ្រោះ ១៣០នាក់***) និងបានបញ្ជូនទៅទទួលសេវាបន្តនៅ អង្គការលុបបំបាត់ការជួញដូរមនុស្សសតវត្សទី២១(A21) អង្គការតំណក់ទឹក អង្គការគ្រួសារថ្មី អង្គការក្តីសង្ឃឹម និងយុត្តធម៌ អង្គការក្តីសង្ឃឹមពិភពលោក អង្គការក្តីស្រឡាញ់គ្មានព្រំដែន និងអង្គការម៉ារីតាន់ភីស ដើម្បីស្នាក់នៅ ទទួលសេវាអប់រំក្នុង និងក្រៅប្រព័ន្ធ និងជំនាញវិជ្ជាជីវៈ មុនពេលធ្វើសមាហរណកម្មត្រឡប់ទៅផ្ទះវិញ។
- **មន្ទីរ ស.អ.យ រាជធានី-ខេត្ត** បានផ្តល់សេវា និងប្រឹក្សាយោបល់រួចបញ្ជូនស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ១០៨នាក់ ទៅទទួលសេវាស្តារនីតិសម្បទាបន្តនៅមណ្ឌល និងអង្គការដៃគូ ក្នុងនោះមាន: មន្ទីរ ស.អ.យ រាជធានីភ្នំពេញ ៣៦នាក់ (***ករណីជួញដូរផ្លូវភេទ ៣១នាក់ និងជួញដូរមនុស្ស ០៥នាក់***) មន្ទីរ ស.អ.យ ខេត្តពោធិ៍សាត់ ០១នាក់(***ករណីរំលោភ***) មន្ទីរ ស.អ.យ ខេត្តស្វាយរៀង ៤៥នាក់ (***ករណីជួញដូរកម្លាំងពលកម្ម***) មន្ទីរ ស.អ.យ ខេត្តក្រចេះ ០៤នាក់ (***ករណីជួញដូរមនុស្ស***) និងមន្ទីរ ស.អ.យ ខេត្តសៀមរាប ២២នាក់ (***ករណីងាយរងគ្រោះ***)។
- អង្គការដៃគូក្រៅរដ្ឋាភិបាល បានទទួលជនរងគ្រោះ និងងាយរងគ្រោះចំនួន ១៣៦នាក់ (ស្ត្រី ៧៨នាក់ កុមារា ០៨ កុមារី ៥០នាក់) ក្នុងនោះមាន: អង្គការបេសកកម្មពិភពលោក ១១នាក់ អង្គការសួននៃក្តីសង្ឃឹមកម្ពុជា ៤៧នាក់ អង្គការពន្លកថ្មី ០៣នាក់ អង្គការសង្គ្រោះជោគវាសនាកម្ពុជា ៤៥នាក់ សមាគមទឹកដីសន្យា ១៣នាក់ និងសមាគមកុមារីរីករាយ ០៨នាក់ (***រួមមានករណី: ធ្វើអាជីវកម្មផ្លូវភេទ ០១នាក់ រំលោភបំពានផ្លូវភេទ ៦៣នាក់ ជួញដូរកម្លាំងពលកម្ម ០១នាក់ ជួញដូរផ្លូវភេទ ១០នាក់ និងជួញដូរមនុស្ស ៦១នាក់***) ដើម្បីផ្តល់សេវាបន្ត ។

**ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ឲ្យទៅតាមសហគមន៍វិញ សរុបចំនួន **១៦៩**នាក់ (ស្ត្រី **១២៩**នាក់និងកុមារី**១៨**នាក់) មានតារាងលម្អិតដូចខាងក្រោមនេះ៖

*តារាងធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរង ឆមាសទី១ ឆ្នាំ២០១៩*

| ក្រសួង ស្ថាប័ន | ជនរងគ្រោះ | | | |
|---|---|---|---|---|
| | សរុប | ស្រី | កុមារា | កុមារី |
| នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃក្រសួង | ១០ | ១០ | ០០ | ០០ |
| មន្ទីរសង្គមកិច្ច រាជធានី-ខេត្ត | ៥៥ | ៤៤ | ០០ | ០៣ |
| អង្គការដៃគូក្រៅរដ្ឋាភិបាល | ១០៤ | ៧៥ | ០០ | ១៥ |
| *សរុប* | *១៦៩ នាក់* | *១២៩ នាក់* | *០០នាក់* | *១៨ នាក់* |

- មន្ត្រីជំនាញរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃក្រសួង ស.អ.យ បានធ្វើសមាហរណកម្មស្ត្រីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ១០នាក់(***ករណីរៀបអាពាហ៍ពិពាហ៍ក្លែងក្លាយ០៦នាក់ និងជួញដូរកម្លាំងពលកម្ម ០៤នាក់***) ឲ្យត្រឡប់ទៅសហគមន៍របស់ខ្លួនវិញ ដោយមានកិច្ច សហការជាមួយអង្គការដៃគូក្នុងការជូនជនរងគ្រោះ ក្នុងនោះមានៈ អង្គការរតនៈអន្តរជាតិ ០៦នាក់ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ ០៣នាក់ និងអង្គការមេត្រីអន្តរជាតិ ០១នាក់។
- **មន្ទីរ ស.អ.យ រាជធានី-ខេត្ត** បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន **៥៥**នាក់ (បុរស ០៨នាក់ ស្រី ៤៤នាក់ កុមារី ០៣នាក់) ដោយមានកិច្ចសហការជាមួយអង្គការដៃគូក្នុងការជូនជនរងគ្រោះ ដូចជាៈ (អង្គការសម្ព័ន្ធចាប់ដៃ អង្គការ អេ.អ.អឹម អង្គការកុមាររីករាយខេត្តបាត់ដំបង អង្គការក្ដីសង្ឃឹម និងយុត្តិធម៌) ក្នុងនោះមានៈ មន្ទីរ ស.អ.យ ខេត្តក្រចេះ ០៤នាក់ មន្ទីរ ស.អ.យ ខេត្តពោធិ៍សាត់០៤នាក់ មន្ទីរស.អ.យ ខេត្តសៀមរាប ០២នាក់(ករណី***រំលោភសេពសន្ថវៈ ០២នាក់ ជួញដូរមនុស្ស ០៦នាក់ និងជួញដូរផ្លូវភេទ ០២នាក់***) និងមន្ទីរ ស.អ.យ ខេត្តស្វាយរៀង ៤៥នាក់ (***ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម***)
- អង្គការដៃគូក្រៅរដ្ឋាភិបាល បានធ្វើសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន **១០៤**នាក់ (បុរស **១៤**នាក់ ស្រី **៧៥**នាក់ កុមារី **១៥**នាក់) ឲ្យត្រឡប់ទៅសហគមន៍របស់ខ្លួនវិញ ក្នុងនោះមានករណីៈ (***ជួញដូរផ្លូវភេទ ២៩នាក់ រំលោភបំពានផ្លូវភេទ ១៣នាក់ ជួញដូរមនុស្ស ៣៣នាក់ ជួញដូរកម្លាំងពលកម្ម ២៦នាក់ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ០៣នាក់***) និងមានៈ អង្គការស្ទួននៃក្តីសង្ឃឹមកម្ពុជា **៣៤**នាក់ អង្គការសង្គ្រោះជោគវាសនានៅកម្ពុជា **២៩**នាក់ អង្គការអេ.អ.អឹម **០២**នាក់ សមាគមទឹកដី សន្យា **០១**នាក់ និងអង្គការរតនៈអន្តរជាតិ **៣៨**នាក់។

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការងារបណ្តុះបណ្តាល

#### ក.១.១. ការបណ្តុះបណ្តាលក្នុងប្រទេស

## តារាងវគ្គបណ្តុះបណ្តាល

| ល.រ | សកម្មភាព | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>- ក្នុងការអនុវត្តគោលនយោបាយអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ (TVET) ក្រសួងបានសហការជាមួយអង្គការ MOI បានជ្រើសរើសសិក្ខាកាមលើកទីពីរ ចំនួន ៤០នាក់ ធ្វើការបណ្តុះបណ្តាលទាំងទ្រឹស្តី ទាំងការអនុវត្តជាក់ស្តែងផ្នែកបដិសណ្ឋាកិច្ច នៅសាលាបណ្តុះបណ្តាលបច្ចេកទេស Paul dudrule នៅខេត្ត សៀមរាបរយៈពេល ០៣ខែ និងបន្តហ្វឹកហាត់ នៅសណ្ឋាគារលំដាប់ផ្កាយ៥ នៅប្រទេសថៃទៀត។<br>- បានសហការជាមួយអង្គការ MOI បើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុក ដល់អ្នកផ្តល់ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអ្នកចូលរួមចំនួន ២៥នាក់(ស្រី ០៩នាក់)។ | ០២ | ៦៥ | ០៩ |
| ២ | **ក្រសួងធម្មការនិងសាសនា** និងគណសង្ឃទាំងពីរគណៈ បានសហការជាមួយអង្គការ UNICEF រៀបចំវគ្គបណ្តុះបណ្តាលស្តីពីកិច្ចការពារកុមារតាមវត្តអារាម ចំនួនពីរវគ្គ ដល់មន្ត្រីសង្ឃ និងមន្ត្រីមន្ត្រីធម្មការនិងសាសនាមកពី២០ខេត្ត។ | ០២ | ១៤០អង្គ/នាក់ | |
| ៣ | **ក្រសួងសុខាភិបាល** បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស និងជួញដូរសរីរាង្គ។ | ០១ | ២៤ | |
| ៤ | **ក្រសួងកិច្ចការនារី**<br>- បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីសកម្មភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា នៅខេត្តស្ទឹងត្រែង ខេត្តបន្ទាយមានជ័យ និងខេត្តតាកែវ បានចំនួន លើក ០៣ លើក អ្នកចូលរួមចំនួន ១២៦នាក់ ស្រី ១០៨នាក់។<br>- កម្មវិធី Safe and Fair ក្រោមកិច្ចសហការក្រសួងកិច្ចការនារី ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គាំទ្រដោយអង្គការ UNWOMEN និងអង្គការ ILO បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពី "ការសម្របសម្រួលការផ្តល់សេវាប្រកបដោយគុណភាពដល់ពលករទេសន្តរប្រវេសន៍ជាស្ត្រី ដែលទទួលរងផលប៉ះពាល់ដោយអំពើហិង្សាលើស្ត្រី" នៅសណ្ឋាគារសាន់វេ ថ្ងៃទី០២-០៣ ខែកក្កដា ឆ្នាំ២០១៩ បានចំនួន លើក ០១ លើកអ្នកចូលរួមចំនួន ៦០នាក់ ស្រី ៣៧នាក់។ | ០៤ | ១៨៦ | ១៤៥ |
| ៥ | **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** បានបើកវគ្គបណ្តុះបណ្តាល ស្តីពីបែបបទនីតិវិធីនៃការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅ៖<br>- ខេត្តត្បូងឃ្មុំ បាន ០១លើក អ្នកចូលរួមចំនួន ៥២នាក់ ស្រី ១៦នាក់។<br>- ខេត្តកំពង់ធំ បាន ០១លើក អ្នកចូលរួមចំនួន ៥១នាក់ ស្រី ៣៦នាក់។ | ០២ | ១០៣ | ៥២ |
| ៦ | **កាកបាទក្រហម៖**បានបើកវគ្គបណ្តុះបណ្តាល ដល់អ្នកស្ម័គ្រចិត្តកាកបាទក្រហម ក្នុងស្រុកគិរីវង្ស ខេត្តតាកែវ ស្តីពីសេវាកម្មស្តារទំនាក់ទំនង និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព។ | ០១ | ២៥ | ០០ |
| ៧ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ០៣ | ៩៦ | ២៥ |

| | | | | |
|---|---|---|---|---|
| | **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន៖**<br>- បានសហការជាមួយអង្គការ (AIM SWAT) បើកវគ្គបណ្តុះបណ្តាល ចំនួន ០២វគ្គ ស្តីពីយុទ្ធវិធីប្រតិបត្តិការ និងការប្រើអាវុធ អ្នកចូលរួមចំនួន ៤០នាក់ ស្រី ០៣នាក់។<br>- បានសហការជាមួយអង្គការ (CPU) បើកវគ្គបណ្តុះបណ្តាល ចំនួន ០១ វគ្គ ស្តីពីការស៊ើបអង្កេតបទល្មើសរំលោភបំពានលើកុមារ អ្នកចូលរួមចំនួន ៥៦នាក់ ស្រី ២២នាក់។ | | | |
| ៨ | **ខេត្តត្បូងឃ្មុំ៖** ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយអង្គការសម្ព័នចាប់ដៃ បើកវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស និងក្រមសីលធម៌ ក្នុងការសម្ភាសកំណត់អត្តសញ្ញាណជនរងគ្រោះ ដល់មន្ត្រីជំនាញទាំង៧ក្រុង ស្រុក នាយប៉ុស្តិ៍ និងមន្ត្រីប៉ុស្តិ៍ នៅស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ | ០១ | ២៧ | ០២ |
| ៩ | **ខេត្តពោធិ៍សាត់៖** មន្ទីរកិច្ចការនារីខេត្ត បានបើកវគ្គបណ្តុះបណ្តាល៖<br>- ថ្នាក់ភូមិ ស្តីពីការបញ្ច្រាបយេនឌ័រ ការធ្វើចំណាកស្រុកដោយដោយសុវត្ថិភាព ព្រមទាំងច្បាប់ជួញដូរមនុស្ស ដល់ មេភូមិ អនុភូមិ និងសមាជិកភូមិ នៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ អ្នកចូលរួមចំនួន ២៥នាក់ ស្រី ០៥នាក់។<br>- ការធ្វើចំណាកស្រុកដោយដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ក្រុមយុវជន នៅឃុំបាក់ជញ្ជៀន ស្រុកភ្នំក្រវាញ អ្នកចូលរួមចំនួន ២៦នាក់ ស្រី ១៦នាក់។ | ០២ | ៥១ | ២១ |
| ១០ | **ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង៖**<br>- បានសហការជាមួយអង្គការ(ឆាលហ្វាន់) បើកវគ្គបណ្តុះបណ្តាលចំនួន ០២វគ្គ ស្តីពីកិច្ចការពារកុមារ ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការជួញដូរកុមារ អ្នកចូលរួមចំនួន ៧៣នាក់ ស្រី ២២នាក់។<br>- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយក្រុមហ៊ុន ចំនួន១៣ នៅតាមបណ្តាតំបន់សេដ្ឋកិច្ចពិសេសនានាក្នុងខេត្ត បើកវគ្គបណ្តុះបណ្តាលចំនួន ០៤វគ្គ ស្តីពីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព អ្នកចូលរួមចំនួន ២៦៨នាក់ ស្រី ១៤២នាក់។ | ០៦ | ៣៤១ | ១៦៤ |
| ១១ | **ខេត្តកោះកុង៖**<br>- ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ចំនួន ០១វគ្គ អ្នកចូលរួមចំនួន ២៤នាក់ ស្រី ១២នាក់។<br>- ពង្រឹងបដិសណ្ឋារកិច្ច និងសុវត្ថិភាពចំណីអាហារ ដោយបានបញ្ច្រាបការយល់ដឹងអំពីការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ នៅសហគមន៍អេកូទេសចរណ៍ជីផាត ឃុំជីផាត ស្រុកថ្មបាំង ចំនួន ០១វគ្គ អ្នកចូលរួមចំនួន ៣៩នាក់ ស្រី ២១នាក់។<br>- ស្តីពីការទប់ស្កាត់អំពើហិង្សា ការរំលោភបំពាន ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ស្រុកស្រែអំបិល និងស្រុកមណ្ឌលសីមា ចំនួន ០៤វគ្គ អ្នកចូលរួមចំនួន ១៨៨នាក់ ស្រី ១០៨នាក់។ | ០៦ | ២៥១ | ១៤១ |

| | | | | |
|---|---|---|---|---|
| | លើគោលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តបន្ទាយមានជ័យ (អ្នកចូលរួមចំនួន ៥៥នាក់ ស្រី ២០នាក់) និង ខេត្តសៀមរាប (អ្នកចូលរួមចំនួន ៦៩នាក់ ស្រី ២៧នាក់)។ | | | |
| ៤. | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>-បានរៀបចំសិក្ខាសាលា ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការ នៅបរទេស តាមរយៈភ្នាក់ងារឯកជន និងបទបញ្ញាផ្សេងៗទៀត ដល់អាជ្ញាធរមូលដ្ឋានថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាននៅក្នុងខេត្តកំពត កំពង់ធំ កំពង់ចាម ព្រៃវែង និង ខេត្តបាត់ដំបង បានចំនួន ០៥លើក ដែលមានអ្នកចូលរួមសរុបចំនួន ៧៧៣នាក់ (ស្រី ២៣៣នាក់។<br>-បានរៀបចំសិក្ខាសាលា ស្តីពីសមាសភាពយេនឌ័រ និងការធ្វើទេសន្តរប្រវេសន៍ការងារ ដល់អ្នកផ្តល់សេវានៅតាមមូលដ្ឋានរបស់ស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល បានចំនួន ០១លើក ដែលមានអ្នកចូលរួម ចំនួន ៣៤នាក់(ស្រី ១៨នាក់)។ | ៦ | ៨០៧ | ២៥១ |
| ៥ | **ក្រសួងកិច្ចការនារី៖** កម្មវិធី Safe and Fair ក្រោមកិច្ចសហការក្រសួងកិច្ចការនារី ជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គាំទ្រដោយអង្គការ UNWOMEN និងអង្គការ ILO បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីកិច្ចការពារសង្គម និងច្បាប់ដល់កម្មករការងារផ្ទះ ឆ្ពោះទៅការផ្តល់សច្ចាប័ននៃអនុសញ្ញា ILO លេខ១៨៩ នៅសណ្ឋាគារសាន់វេ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៩។ | ០១ | ៥៩ | ២៦ |
| ៦ | **ក្រសួងទេសចរណ៍** បានរៀបចំសិក្ខាសាលា ស្តីពី "សុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ ជូនដល់ម្ចាស់មូលដ្ឋានអាជីវកម្ម សេវាកម្មទេសចរណ៍ មន្ទីរ អង្គភាព សមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរដែនដី និងយុវជន ដែលមានសិក្ខាកាមចូលរួម មកពីតាមបណ្តាខេត្តចំនួន ០៣ មានៈ ខេត្តកំពង់ស្ពឺ ប៉ៃលិន និងខេត្តបន្ទាយមានជ័យ។ | ០៣ | ២៤៨ | ១៣៦ |
| ៧ | **ក្រុមប្រឹក្សាជាតិដើម្បីកុមារ** បានសហការជាមួយ UNICEF រៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ពន្ធ័ ស្តីពីការទប់ស្កាត់ និងឆ្លើយតបចំពោះការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រពន្ធ័អ៊ីនធើណែត។ | ០១ | ៩៥ | ០០ |
| ៨ | **អគ្គស្នងការដ្ឋាននគរបាលជាតិ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន**<br>-បានសហការជាមួយអង្គការ(Hope for justice) បើកវគ្គសិក្ខាសាលា ស្តីពីការជួញដូរមនុស្សនាសម័យទំនើប (អ្នកចូលរួមចំនួន ៧០នាក់ ស្រី ៥០ នាក់) នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>-បានសហការជាមួយអង្គការ (APLE) បើកវគ្គសិក្ខាសាលា ស្តីពីកិច្ចសហប្រតិបត្តិការពហុស្ថាប័ន ក្នុងការការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ ក្នុងវិស័យទេសចរណ៍ (អ្នកចូលរួមចំនួន ៦៥នាក់ ស្រី ៣២នាក់) នៅភោជនីយដ្ឋាន ទន្លេបាសាក់១។ | ០២ | ១៣៥ | ៨២ |
| ៩ | **ខេត្តបាត់ដំបង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការងារ និងច្បាប់ស្តីពីអន្តោប្រវេសន៍ ដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ជនបរទេស ឬជនបរទេស ដែលប្រកបមុខរបរណាមួយនៅបណ្តាស្រុកជាប់ព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តបាត់ដំបង នៅក្នុងបរិវេណសាលាស្រុកភ្នំព្រឹក។ | ០១ | ១០០ | ០៥ |
| ១០ | **ខេត្តប៉ៃលិន៖ មន្ទីរទេសចរណ៍ខេត្ត** បានរៀបចំសិក្ខាសាលា ស្តីពីសុវត្ថិភាពកុមារ | ០១ | ៨០ | ៤០ |

| | | | | |
|---|---|---|---|---|
| | និងបានបញ្ច្រាបការធ្វើចំណាកស្រុកដោយស្របច្បាប់ ក្នុងវិស័យទេសចរណ៍។ | | | |
| ១១ | **ខេត្តកោះកុង៖** មន្ទីរទេសចរណ៍ខេត្ត រៀបចំសិក្ខាសាលាស្តីពី ការយល់ដឹងអំពីការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ នៅឃុំប៉ាក់ខ្លង។ | ០១ | ២៧ | ១១ |
| | សរុប | ២២វគ្គ | ១.៩៧៥នាក់ | ៨៤៥នាក់ |

### ក.២.២. សិក្ខាសាលាក្រៅប្រទេស

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**
  - បានចាត់មន្ត្រីជំនាញទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់មេគង្គ លើកទី០៩ ស្តីពីសំណាញ់ឯកភាព ឆ្ពោះទៅមុខនៃការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។
  - បានចាត់ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត ដើម្បីទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់ស្តីពីមជ្ឈមណ្ឌលធនធានសម្រាប់ពលករ នៅខេត្តង៉េអាន ប្រទេសវៀតណាម។

## ខ. សន្និសីទ កិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១ សន្និសីទថ្នាក់ជាតិ និងអន្តរជាតិ

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាអធិបតីភាពបើកអង្គសន្និសីទអន្តរជាតិកិច្ចសហប្រតិបត្តិការទ្វេភាគីលើកទី២ កម្ពុជា-ថៃ ស្តីពីទេសន្តរប្រវេសន៍ការងារ និងអំពើជួញដូរមនុស្ស ដែលមានការចូលរួមពីតំណាងមន្ទីរការងារប្រទេសថៃ តំណាងភាគីកម្ពុជា អាជ្ញាធរមានសមត្ថកិច្ច ប្រតិភូសហភាពអឺរ៉ុប ទីភ្នាក់ងារអង្គការសហប្រជាជាតិ តំណាងអង្គការសង្គមស៊ីវិល វិស័យឯកជន សរុបអ្នកចូលរួមប្រមាណ **៧០** នាក់ នៅសណ្ឋាគារ AngKor Miracle ខេត្តសៀមរាប។

### ខ.២. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

➢ **កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈអន្តរជាតិ**

- **ថ្នាក់ជាតិ**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំកិច្ចប្រជុំ៖

- រវាង ភាគីពាក់ព័ន្ធ កម្ពុជា ថៃ ដើម្បីពង្រឹងកិច្ចសហការ ក្នុងការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ជាមួយគណៈប្រតិភូថៃ ដោយមានការអញ្ជើញចូលរួមចំនួន **៥៩**នាក់ នៅទីស្តីការក្រសួងមហាផ្ទៃ។
- បូកសរុបលទ្ធផលនៃទស្សនកិច្ចជាមួយភាគីថៃ រយៈពេល២ថ្ងៃ និងអភិវឌ្ឍន៍ផែនការសកម្មភាព អ្នកចូលរួមចំនួន **៥៩**នាក់ នៅភោជនីយដ្ឋាន ទន្លេបាសាក់២។
- បូកសរុបលទ្ធផលនៃទស្សនកិច្ចជាមួយភាគីថៃ រយៈពេ៣ថ្ងៃ និងអភិវឌ្ឍន៍ផែនការសកម្មភាព អ្នកចូលរួមចំនួន **៦០**នាក់ នៅភោជនីយដ្ឋាន ទន្លេបាសាក់១។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

បានរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសមន្ត្រីជាន់ខ្ពស់កម្ពុជា-ថៃ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការវិស័យការងារ និងកិច្ចព្រមព្រៀង ស្តីពីការប្រើប្រាស់

កម្លាំងពលកម្ម ដើម្បីពិនិត្យ និងដោះស្រាយបញ្ហានានា ដែលកើតឡើង និងទប់ស្កាត់រាល់បញ្ហា ដែលអាចកើតឡើងជាយថាហេតុ។

- **ថ្នាក់ក្រោមជាតិ**

▪ **ខេត្តព្រះវិហារ**

រដ្ឋបាលខេត្ត និងសមត្ថកិច្ចច្រកទ្វារព្រំដែនតំបន់អានសេះ បានជួបប្រជុំជាមួយភាគីថៃ ស្តីពីកិច្ចសហប្រតិបត្តិការការពារសន្តិសុខតាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដើម្បីស្វែងការងារធ្វើក្រៅប្រទេស និងពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្លងដែនខុសច្បាប់ ចំនួន០១លើក មនុស្សចូលរួមចំនួន ៣៨នាក់ នៅខេត្តព្រះវិហារ។

➢ **កិច្ចប្រជុំក្នុងប្រទេសជាលក្ខណៈជាតិ**

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

- **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ថ្នាក់ជាតិ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៨ និងលើកទិសដៅអនុវត្ត ឆ្នាំ២០១៩ ដែលមានអ្នកចូលរួមចំនួន ៣៦៩នាក់ (ស្រី ១១៩នាក់) នៅទីស្តីការក្រសួងមហាផ្ទៃ។
- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមដឹកនាំៈ

**កិច្ចប្រជុំពិភាក្សាអន្តរក្រសួង** (នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ)

- ស្តីពីការពិគ្រោះយោបល់សម្រាប់ការរៀបចំកិច្ចប្រជុំពិភាក្សាលើកទី២ ស្តីពី "**ប្រទេសបញ្ជូន កម្ពុជា ឡាវ ភូមា**" អ្នកចូលរួមចំនួន ៣២នាក់ (ស្រី ០៥នាក់)។
- ស្តីពីការរកវិធានការគ្រប់គ្រងលំហូរពលករកម្ពុជា អំឡុងពេលមកចូលរួមអបអរក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរ និងពេលត្រឡប់ទៅវិញ។
- ស្តីពីករណីពលករកម្ពុជាចំនួន ០២នាក់ បានស្លាប់ក្នុងពេលបំពេញការងារនៅប្រទេសថៃ កាលពីឆ្នាំ២០១៧ អ្នកចូលរួមចំនួន ១៤នាក់ (ស្រី ០៤នាក់)។
- ស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីសេវាសង្គម ដើម្បីលើកកម្ពស់ការឆ្លើយតបទៅនឹងផលប៉ះពាល់លើកុមារក្នុងទេសន្តរប្រវេសន៍ អ្នកចូលរួមចំនួន ២៨នាក់ (ស្រី ០៧នាក)។
- ដើម្បីទទួលគណៈប្រតិភូនាយកសាលា និងគ្រូបង្រៀន ១៣សាលារៀន ពីប្រទេសថៃ ក្រោមកិច្ចសហការពីអង្គការមូលនិធិបណ្តាញលើកកម្ពស់សិទ្ធិពលកម្ម (LPN) និងអង្គការ Plan អន្តរជាតិ ដែលនឹងមកទស្សនកិច្ចនៅតាមសាលារៀន និងសហគមន៍ ដែលមានបណ្តាញ គាំពារសង្គមមួយចំនួននៅរាជធានីភ្នំពេញ អ្នកចូលរួមចំនួន ២៦នាក់ (ស្រី ០៦នាក់)។

**កិច្ចប្រជុំផ្ទៃក្នុង**

- ស្តីពីយន្តការនៃការគ្រប់គ្រងមណ្ឌលទទួលពលករបញ្ជូនត្រឡប់ដោយអាជ្ញាធរថៃ និងប្រកាសផ្សព្វផ្សាយអំពីសេចក្តីសម្រេចលេខ ១៦៨/១៧ សសរ ស្តីពីការបង្កើតក្រុមការងារទទួលពលករពលការិនីកម្ពុជាខុសច្បាប់មកពីប្រទេសថៃ និងសេចក្តីសម្រេចលេខ ២០៩/១៨ សសរ ស្តីពីការបង្កើតក្រុមការងារចម្រុះប្រចាំការទទួលពលករ ពលការិនីកម្ពុជាបញ្ជូនមកពីប្រទេសថៃ នៅខេត្តបន្ទាយមានជ័យ។
- ស្តីពីការកែសម្រួលខ្លឹមសាររបាយការណ៍ប្រចាំឆ្នាំ២០១៨ និងលើកទិសដៅឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០៣លើក។

- ដើម្បីឆ្លើយតបសំណួររបស់ស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ក្នុងការរៀបចំបទបង្ហាញក្នុងកិច្ចប្រជុំទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅប្រទេសថៃ។
- ពិនិត្យតារាងសកម្មភាព នៃផែនការយុទ្ធសាស្ត្រ៥ឆ្នាំ(បន្តបញ្ចប់) និងបន្ថែមការកែសម្រួលបំពេញចន្លោះ ដែលត្រូវការទិន្នន័យតាមចំណុចនៃការងារពាក់ព័ន្ធក្រុមនីមួយៗ អ្នកចូលរួមចំនួន **១៤**នាក់ (ស្រី ០៤នាក់)។
- ពិនិត្យលទ្ធផល និងការផ្តល់ពិន្ទុ នៃការវាយតម្លៃសកម្មភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់គ.រ.ប.ជ/គ.ខ.ប.ជ អ្នកចូលរួមចំនួន **២១**នាក់ (ស្រី ០៣នាក់)។
- ស្តីពីរបាយការណ៍ការងារសង្ខេបខ្លីគ្រប់ក្រុម អ្នកចូលរួមចំនួន **២៥**នាក់ (ស្រី ០៣នាក់)។
- ស្តីពីសំណួរ ចម្លើយ របស់ UN អ្នកចូលរួមចំនួន **១៣**នាក់ (០៤នាក់)។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ) បានរៀបចំកិច្ចប្រជុំ៖**
  - ត្រីមាសទី១ ដែលដឹកនាំដោយ **ឯកឧត្តម ឯក គ្រិស្ប** រដ្ឋលេខាធិការក្រសួង ស.អ.យ ដោយបានសហការជាមួយក្រុមការងារការពារជនរងគ្រោះរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងមានអ្នកចូលរួមមកពីបណ្តាក្រសួង ស្ថាប័ន និងអង្គការដៃគូពាកព័ន្ធ ចំនួន **៤៧**នាក់(ស្រី**២៦**នាក់)។
  - ត្រីមាសទី១ ស្តីពីកិច្ចសហការ និងត្រួតពិនិត្យ តាមដានការអនុវត្តសកម្មភាពការងាររបស់អង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួង ស.អ.យ មានអ្នកចូលរួមមកពីបណ្តាក្រសួង ស្ថាប័ន និងអង្គការដៃគូពាកព័ន្ធ ចំនួន **៦៦**នាក់(ស្រី **៣៧**នាក់)។
  - ស្តីពីការចុះកិច្ចព្រមព្រៀង រវាងក្រសួង ស.អ.យ ជាមួយអង្គការសួននៃក្តីសង្ឃឹមនៅកម្ពុជា នៅទីស្តីការក្រសួង មានអ្នកចូលរួមមកពីមន្ត្រីជំនាញ និងអង្គការដៃគូចំនួន **១៧**នាក់(ស្រី **១០**នាក់)។
  - ស្តីពីការធ្វើបច្ចុប្បន្នភាពលើទម្រង់ទទួល តាមដាន និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស លើកទី៦ មានអ្នកចូលរួមមកពីមន្ត្រីជំនាញរបស់នាយកដ្ឋាន និងអង្គការដៃគូពាក់ព័ន្ធចំនួន **២៧**នាក់ ក្នុងនោះដឹកនាំដោយ **ឯកឧត្តម តូច ចាន់នី ចំនួន ១លើក** ។
- **ក្រសួងអប់រំយុវជន និងកីឡា បានរៀបចំកិច្ចប្រជុំ៖**
  - អន្តរក្រសួងស្តីពីការរៀបចំ ផែនសកម្មភាពការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស២០១៩-២០២៣ នៅអគាររដ្ឋបាលក្រសួងអប់រំ។
  - រៀបចំប្រជុំពិនិត្យ និងសម្រេចលើកចុងក្រោយ លើផែនការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល៥ឆ្នាំ ២០១៩-២០២៣ ។
- **ក្រសួងសុខាភិបាល** បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីប្រមូលទិន្នន័យ សម្រាប់បំពេញរបាយការណ៍សកល ស្តីពីការការពារអំពើហិង្សាលើកុមារ នៅទីស្តីការក្រសួងសុខាភិបាល។

➢ **កិច្ចប្រជុំក្រៅប្រទេស**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

  លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - ជាគណៈប្រតិភូរបស់កម្ពុជា ក្នុងកិច្ចប្រជុំពិភពលោកឆ្នាំ២០១៩ ស្តីពី "**សន្តិភាព សន្តិសុខ និងការអភិវឌ្ឍជនជានមនុស្ស**" នាទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ នៅក្នុងកិច្ចប្រជុំនេះមានការចូលរួមពី ប្រមុខរដ្ឋ និងអតីតប្រមុខរដ្ឋ សមាជិកសភា សមាជិកព្រឹទ្ធសភា មេដឹកនាំស្ត្រី និងមេដឹកនាំសង្គមស៊ីវិល រៀបចំដោយសហព័ន្ធសន្តិភាពសកល (UPF) ដែលជាអង្គការសហប្រជាជាតិឆ្នាំ២០១៩។

○ ដឹកនាំប្រតិភូអគ្គលេខាធិការ គ.ជ.ប.ជ ដើម្បីទៅចូលរួមក្នុងកិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយសកម្មភាពថ្មី ក្នុងការរួមគ្នាប្រឆាំងអំពើទាសភាពសម័យទំនើប ក្នុងសង្វាក់ផលិតកម្ម ដែលធ្វើឡើងនៅក្នុងប្រទេសអូស្ត្រាលី ដែលមានសមាសភាពចូលរួមប្រមាណជាង ៤០០នាក់ មកពី ២០ប្រទេសផ្សេងគ្នាជុំវិញពិភពលោក។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)**

- បានចូលរួមកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់លើកទី១៣ និងការពិនិត្យឡើងវិញនូវយុទ្ធនាការស៊ើបអង្កេតរួមគ្នារបស់ខមមីតឆ្នាំ២០១៨ នៅទីក្រុងណានចាង សាធារណរដ្ឋប្រជាមានិតចិន។
- ឯកឧត្តម **ញ៉ឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដឹកនាំគណៈប្រតិភូព្រះរាជាណាចក្រកម្ពុជា សរុបចំនួន **២៥**នាក់ (ស្រី **០៧**នាក់) តំណាងមកពីៈ (ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងយុត្តិធម៌ និងក្រសួងសុខាភិបាល) គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ស្ថានទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ អង្គការ IOM និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីទៅចូលរួមកិច្ចប្រជុំ ស្តីពីពិធីចុះហត្ថលេខាលើនីតិវិធីប្រតិបត្តិបទដ្ឋាន ស្តីពីដំណើរការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ។

- **ក្រសួងការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**

បានប្រជុំថ្នាក់រដ្ឋមន្ត្រីចំនួន៣លើក និងថ្នាក់មន្ត្រីជាន់ខ្ពស់ចំនួន៣លើកបនៅប្រទេសម៉ាឡេស៊ី ដើម្បីអនុត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី។

- **ក្រសួងកិច្ចការនារី (ត្រីមាសទី១)**

លោកជំទាវ **សាន្ត អរុណ** រដ្ឋលេខាធិការស្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារខមមីត បានដឹកនាំគណៈប្រតិភូកម្ពុជា មានថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ចំនួន **០២**រូប ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គស្នងការដ្ឋាននគរបាលជាតិ អង្គការ UN-ACT និងអង្គការចាប់ដៃ សរុបចំនួន **១៤**រូប (ស្រី **០៧**រូប) ដើម្បីទៅចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ខមមីតលើកទី១៣ និងពិនិត្យមើលឡើងវិញនូវសកម្មភាពស៊ើបអង្កេតរួមគ្នារវាងប្រទេសសមាជិកទាំង៦ (COMMIT Regional Taskforce Meeting និង COMMIT Senior Officials Meeting(SOM13) នៅខេត្តជាំងស៊ី នៃសាធារណរដ្ឋប្រជាមានិតចិន។

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

បានចាត់បញ្ជូនថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋាន ចំនួន **០២**រូប និង Cambodia Acts **០២**រូប អង្គការ Cambodia Acts **០១**រូប និងអង្គការជាសមាជិករបស់ Cambodia Acts **០៥**រូប សរុបចំនួន **១០**រូប (ស្រី **០៩**រូប) ទៅចូលរួមកិច្ចប្រជុំ Reflection Between Cambodia-Thai (Annual Cross Border Meeting Between Cambodia and Thailand) នៅខេត្តត្រាត និងខេត្តរ៉ាក់យ៉ង ប្រទេសថៃ។

## ២.៣. ការទទួលជួបពិភាក្សាការងារ

▪ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអនុញ្ញាតិទទួលជួបពិភាក្សាការងារជាមួយៈ

- អង្គការ ហេបភីទ្រី ដែលមានលោក **Jerry Vong** ជាប្រធានដើម្បីសិក្សា រកចំណុចដែលអាចសហការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងការចូលរួមជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- តំណាងស្ថានទូតអាមេរិកប្រចាំកម្ពុជា ចំនួន **០២**លើក ស្តីពីកិច្ចសហប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- តំណាងស្ថានទូតអូស្ត្រាលីនិងរដ្ឋាភិបាល លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- អង្គការ Child Fund កម្ពុជា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- អង្គការ ការីតាស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

## ២.៤. ទស្សនកិច្ចក្នុងប្រទេស និងក្រៅប្រទេស

▪ **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)**

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចុះទស្សនកិច្ចការងារដល់ទីតាំងទទួលពលករ និងបានជួបប្រជុំពិភាក្សាការងារដើម្បីពង្រឹងកិច្ចសហការ រវាងស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងអង្គការដៃគូក្នុងការងារទទួល និងផ្តល់សេវា ដល់ពលករបញ្ជូនត្រលប់ និងផ្តល់កិត្តិយសប្រគល់លិខិតថ្លែងអំណរគុណរបស់ គណៈកម្មាធិការជាតិ ដល់តំណាងក្រុមហ៊ុន **សុខ ស្រេង** ដែលបានផ្តល់ទីតាំងក្នុងការបំពេញការងារ នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

## ២.៥. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេស គឺ **១៧៤**លើក មានអ្នកចូលរួមសរុប **៧.៥៨០**នាក់ (ស្រី **១.១៦៥**នាក់) ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **៩៤**លើក ក្រសួងអប់រំ យុវជន និងកីឡា **២០**លើក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **០៣**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **០៤**លើក ក្រសួងពត៌មាន **០៣**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **៥០**លើក។ (ឧបសម្ព័ន្ធ១)

# III. ការសន្និដ្ឋានវាយតម្លៃ

លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងឆមាសទី១ ក្នុងឆ្នាំ២០១៩នេះ បានបង្ហាញឲ្យឃើញពីកិច្ចខិតខំប្រឹងប្រែងរបស់គ្រប់ភាគីពាក់ព័ន្ធនៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបានធ្វើឲ្យមានលទ្ធផលគួរជាទីមោទនៈ ដែលអាចវាយតម្លៃបានដូចខាងក្រោមៈ

## ក. ចំណុចខ្លាំង

- ការប្តេជ្ញាចិត្តរបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី ក៏ដូច ជាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិ (គ.ជ.ប.ជ) ក៏ដូចជាថ្នាក់ដឹកនាំគ្រប់ក្រសួង ស្ថាប័ន អង្គភាពក្នុងគណៈកម្មាធិការជាតិ និងថ្នាក់ក្រោមជាតិក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងបទល្មើសពាក់ព័ន្ធទាំងឡាយ បានលើកទឹកចិត្ត ឲ្យការខិតខំប្រឹងប្រែងរបស់មន្ត្រីអនុវត្តគ្រប់ថ្នាក់ មានកម្លាំងចិត្ត និងឆន្ទៈ

មុះមុតក្នុងការបន្តអនុវត្តសកម្មភាពដើម្បីការពារសន្តិសុខ សុវត្ថិភាពជូនប្រជាពលរដ្ឋពីអំពើជួញដូរមនុស្ស គ្រប់រូបភាព។

- គ្រប់ក្រសួង ស្ថាប័ន អង្គភាព ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជាអង្គការដៃគូ ទាំងឡាយ នៅតែបន្តប្រឹងប្រែងដោះស្រាយបញ្ហានៅមូលដ្ឋាន និងអប់រំផ្សព្វផ្សាយតាមគ្រប់វិធីប្រកបដោយឆន្ទៈខ្ពស់ ដើម្បីឲ្យប្រជាពលរដ្ឋ ក៏ដូចជាអាជ្ញាធរគ្រប់លំដាប់ថ្នាក់ បានយល់ដឹងអំពីអំពើជួញដូរមនុស្ស និងផលវិបាក ទាំងឡាយ ដើម្បីនាំគ្នាបង្ការទប់ស្កាត់
- កម្លាំងសមត្ថកិច្ច បន្តខិតខំស្រាវជ្រាវ និងបង្កើនការបង្ក្រាប រហូតទទួលបានលទ្ធផល គួរជាទីមោទនៈ
- តុលាការរាជធានីខេត្ត បានខិតខំបង្កើនសវនាការផ្តន្ទាទោសជនល្មើស ទាំងករណីចាស់ ករណីថ្មី បាន កាន់តែប្រសើរឡើង
- ក្រសួងស្ថាប័ន ពាក់ព័ន្ធ អាជ្ញាធរដែនដី និងអង្គការដៃគូពាក់ព័ន្ធ បានសហការគ្នាបង្កើនគុណភាព នៃ ការផ្តល់សេវាជូនជនរងគ្រោះ តាមគ្រប់រូបភាព ទាំងសេវាសុខភាព សេវាសង្គមកិច្ច សេវាច្បាប់ និង សេវាសេដ្ឋកិច្ចលើកកម្ពស់ជីវភាព បានកាន់តែច្រើន ។
- ប្រទេសពាក់ព័ន្ធ និងអន្តរជាតិ ក៏បាន និងកំពុងខិតខំកែលម្អនីតិវិធី និងបទដ្ឋាននានា ដែលបម្រើឲ្យ សុវត្ថិភាពពលករ នៅក្នុងប្រទេសគោលដៅ និងការសង្គ្រោះជនរងគ្រោះ។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទោះបីជាមានលទ្ធផលល្អប្រសើរយ៉ាងនេះក្តី ក៏នៅមានភាពប្រឈម និងចំណុចខ្វះចន្លោះ ដែលចាំបាច់ត្រូវបំពេញបន្ថែម ដូចខាងក្រោម ៖

- ការវាយតម្លៃពីសហរដ្ឋអាមេរិក លើកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល បានទម្លាក់ចំណាត់ថ្នាក់ ពី លេខ២ (បីឆ្នាំជាប់គ្នា) មកលេខ២ក្នុងការឃ្លាំមើល ដែលគេបានបញ្ជាក់ថា កម្ពុជា នៅមាន ចំណុចខ្វះខាតមួយចំនួន ក្នុងប្រតិបត្តិការ មានជាអាទិ៍៖ នៅមានមន្ត្រីឃុបឃិត សមគំនិតជាប្រព័ន្ធ ជាមួយឈ្មួញដែលអសីលធម៌ និងមានអំពើពុករលួយក្នុងប្រតិបត្តិការ អនុវត្តច្បាប់ ដំណើរការក្តីក្នុង ប្រព័ន្ធតុលាការ និងការផ្តល់សេវាជូនជនរងគ្រោះ ដែលជាមូលហេតុ ដែលនាំឲ្យជនរងគ្រោះ នៅតែ បន្តរងគ្រោះដោយអំពើជួញដូរមនុស្ស ទាំងនៅក្នុងប្រទេស ទាំងក្នុងប្រទេសគោលដៅ។

  ការវាយតម្លៃនេះ ក៏បានធ្វើឲ្យមន្ត្រីដែលកំពុងតែសកម្មការងារ ប្រកបដោយឆន្ទៈខ្ពស់ មានការបាក់ ទឹកចិត្តជាខ្លាំង តែទន្ទឹមនឹងនោះ ក៏ទាមទារឲ្យមានការប្រឹងប្រែងបន្ថែមទៀត ដើម្បីកែលម្អចំណុចខ្វះ ខាត ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ការប្តេជ្ញាចិត្ត និងកិច្ចខំប្រឹងប្រែងជារួម របស់រាជរដ្ឋាភិបាល ។
- បទល្មើសជួញដូរមនុស្ស ដែលបានក្លាយជាទាសភាពសម័យទំនើប បាន និងកំពុងតែកើតមាននៅ គ្រប់តំបន់ទូទាំងពិភពលោក និងបានរីកសាយភាយ ប្រទាក់ក្រឡាគ្នា យ៉ាងស្មុគស្មាញ និងច្របូក ច្របល់ រវាងបទល្មើសនីមួយៗ ។
- សមត្ថភាពក្នុងការវិភាគស្ថានភាព ការដាក់វិធានការ និងការត្រៀមខ្លួនសម្រាប់បង្ការទប់ស្កាត់ចរន្តនៃ បទល្មើសរបស់ សមត្ថកិច្ចយើង នៅមានកម្រិត ។
- កិច្ចសហការរវាងក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅមិនទាន់គ្រប់គ្រាន់ នៅ មើលបំណាំគ្នា ក្នុងការស្វែងរកបញ្ហា និងដំណោះស្រាយរួមគ្នា ដែលធ្វើឲ្យជនល្មើស នៅតែអាចឆ្លៀត ឱកាសធ្វើសកម្មភាពបានជាបន្តបន្ទាប់ ។
- ការចែករំលែកព័ត៌មាន និងរបាយការណ៍នៅយឺតយ៉ាវ មិនទាន់សភាពការណ៍ ។
- ថ្នាក់ដឹកនាំ និងមន្ត្រីដែលទើបនឹងទទួលបន្ទុកការងារប្រឆាំងការជួញដូរមនុស្ស តាមបណ្តាក្រសួង អង្គភាព ស្ថាប័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវការការបណ្តុះបណ្តាល និងស្វែងយល់

បន្ថែមទៀតអំពី តួនាទី ភារកិច្ច ដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសម្រេចនានា ដើម្បីពង្រឹងការងារឲ្យបានល្អប្រសើរ ។

## IV. ទិសដៅឆមាសទី២ ឆ្នាំ ២០១៩

១. បន្តពង្រឹងស្ថាប័ន និងពង្រីកកិច្ចសហការទូលំទូលាយរវាងសមាជិកក្នុងក្រុមការងារអន្តរស្ថាប័នទាំង០៦ និងគណៈកម្មាធិការថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) ដោយបង្កើនការយកចិត្តទុកដាក់រៀបចំកិច្ចប្រជុំក្រុមការងារជាប្រចាំ និងផ្តល់របាយការណ៍មកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ប្រចាំខែត្រីមាស ឆមាស និងប្រចាំឆ្នាំឲ្យបានទៀងទាត់ ។

២. បន្តរៀបចំ និងពន្លឿនការអនុម័តច្បាប់សំខាន់ៗ និងបន្តរៀបចំបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ។

៣. រៀបចំផែនការអនុវត្ត ផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ក្នុងផែនការជាតិ ។

៤. ពង្រឹងប្រសិទ្ធភាពនៃការដឹកនាំបញ្ជា និងការអនុវត្ត នូវវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ។

៥. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន (កម្ពុជា ឡាវ ភូមា) ដើម្បីពង្រឹងកិច្ចសហការដោះស្រាយបញ្ហារួម ចែករំលែកបទពិសោធន៍ក្នុងការគ្រប់គ្រងលំហូរមិនប្រក្រតីរបស់ពលករ និងកិច្ចការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងវិស័យឧស្សាហកម្មនេសាទក្នុងប្រទេសគោលដៅ ។

៦. ត្រៀមកិច្ចប្រជុំបីប្រទេស កម្ពុជា វៀតណាម ចិន ក្នុងការពង្រឹងកិច្ចសហការការពារ និងបង្ការទប់ស្កាត់ ការនាំមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេស ទារក និងស្ត្រី ។

៧. បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធ ដល់មន្ត្រីទទួលបន្ទុកអនុវត្តថ្នាក់ក្រោមជាតិ លើការងារលេខាធិការដ្ឋាន របាយការណ៍ ផែនការ ការងារត្រួតពិនិត្យ និងពង្រឹងការងារជំនាញសម្រាប់អនុវត្តយុទ្ធសាស្ត្រទាំងបួន ។

៨. បន្តលើកកម្ពស់ការងារផ្សព្វផ្សាយ ច្បាប់ គោលនយោបាយ និងពង្រីកការអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៩. បន្តបើកវគ្គបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួងស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

១០. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញា និងផែនការអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

១១. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ ដើម្បីការពារសុវត្ថិ។

១២. បន្តរៀបចំវិធានការ **"គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី"** (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១៣. សិក្ខាសាលាពិគ្រោះយោបល់ រកវិធានការទប់ស្កាត់ ការរំលោភ និងការធ្វើអាជីវកម្មផ្លូវភេទ លើកុមារ ។
១៤. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមកក្នុង វិស័យ យុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។
១៥. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល និងការចុះតាមដានការអនុវត្តគោលនយោបាយ នៅថ្នាក់ក្រោមជាតិ ។
១៦. ពង្រឹងសកម្មភាពទទួលពលករ ការស្រាវជ្រាវទិន្នន័យ និងផ្តល់សេវាជូនពលករដែលត្រូវបានបញ្ជូនត្រឡប់ពីអាជ្ញាធរបរទេស និងពលកររិលត្រឡប់វិញនៅតាមច្រកព្រំដែនសំខាន់ៗ ។

ថ្ងៃ..[illegible]..ខែ..[illegible]..ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ..[illegible].. ឆ្នាំ២០១៩
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**
- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារគ.ជ.ប.ជ
-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ